ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១

## និងទិសដៅអនុវត្តបន្ត

រៀបចំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# មាតិកា


**បញ្ជីតារាង** ..... iii

**I-លទ្ធផលការងារ** ..... 1

កម្មវិធីទី១. ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ..... 1

អនុកម្មវិធីទី១.១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ ..... 1

១.១.១.ការងារសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះ និងងាយរងគ្រោះ ..... 1

១.១.២.ការងារជនអនាថា ..... 2

១.១.៣.ការទប់ស្កាត់ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ ..... 2

១.១.៤.ការងារគ្រួសារ និងយេនឌ័រ ..... 2

១.១.៤.ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការធ្វើសមាហរណកម្មជនរងគ្រោះ ..... 3

អនុកម្មវិធីទី១.២.ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា ..... 4

១.២.១.ការងារមជ្ឈមណ្ឌលកុមារកំព្រា និងការថែទាំកុមារ ..... 4

១.២.២.ការងារថែទាំជំនួសចំពោះកុមារ និងអធិការកិច្ច ..... 4

១.២.៣ ការងារសុំកូនអន្តរប្រទេស ..... 6

១.២.៤ ការងារក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក ជ ក) ..... 6

១.២.៥.ការងារយុវនីតិសម្បទា ..... 7

១.២.៥.១.ការអប់រំ ទប់ស្កាត់កុមារ យុវជនប្រព្រឹត្តបទល្មើស និងសេពគ្រឿងញៀន ..... 7

១.២.៥.២.ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ..... 7

អនុកម្មវិធីទី១.៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ ..... 8

អនុកម្មវិធីទី១.៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់ ..... 10

អនុកម្មវិធីទី១.៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន ..... 10

កម្មវិធីទី២. ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ .. 10

អនុកម្មវិធីទី២.១.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ..... 10

អនុកម្មវិធីទី២.២. ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ ..... 11

អនុកម្មវិធីទី២.៣.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ ..... 12

២.៣.១.ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ..... 12

២.៣.២. ការផ្តល់សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ ..... 13

២.៣.៣.ការផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍ ..... 13

កម្មវិធីទី៣. ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូ ..... 13

អនុកម្មវិធីទី៣.១. ការពង្រឹងសមត្ថភាពស្ថាប័ន និងភាពជាដៃគូ ..... 13

៣.១.១. ការងាររដ្ឋបាល និងបុគ្គលិក ..... 13

៣.១.២. ការងារផែនការ ស្ថិតិ និងសរុប ..... 13
៣.១.៣.ការងារគ្រប់គ្រងថវិកា និងសម្ភារ ..... 14
៣.១.៤ ការងារសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន ..... 14
៣.១.៥. សវនកម្មផ្ទៃក្នុង ..... 15
៣.១.៦. ការងារអធិការកិច្ច ..... 15
អនុកម្មវិធីទី៣.២.ការអភិវឌ្ឍធនធានមនុស្ស ..... 15
**II-ទិសដៅអនុវត្តបន្ត** ..... 15
កម្មវិធីទី១. ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ..... 15
អនុកម្មវិធីទី១.១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ_និងកិច្ចការគ្រួសារ ..... 15
អនុកម្មវិធីទី១.២.ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា ..... 16
អនុកម្មវិធីទី១.៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ ..... 17
អនុកម្មវិធីទី១.៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់ ..... 17
អនុកម្មវិធីទី១.៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន ..... 18
កម្មវិធីទី២. ការបង្កើនប្រសិទ្ធិភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ .. 18
អនុកម្មវិធីទី២.១. ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ..... 18
អនុកម្មវិធីទី២.២.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ ..... 18
អនុកម្មវិធីទី២.៣.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ ..... 18
កម្មវិធីទី៣ ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូ ..... 19
អនុកម្មវិធីទី៣.១.ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងភាពជាដៃគូ ..... 19
អនុកម្មវិធីទី៣.២.ការអភិវឌ្ឍធនធានមនុស្ស ..... 19
**តារាងឧបសម្ព័ន្ធម៉ាទ្រិចស្តីពីការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធី** ..... 20

# បញ្ជីតារាង


តារាងទី១៖ ជំនួយសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះ និងងាយរងគ្រោះ ............................................................ 1
តារាងទី២៖ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ០២ឆ្នាំ ទទួលបានប្រាក់ឧបត្ថម្ភកម្មវិធី ក្នុងឆ្នាំ២០២១ ............................ 3
តារាងទី៣៖ ការឧបត្ថម្ភរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជូនមណ្ឌលកុមារកំព្រា ........................... 4
តារាងទី៤ ៖ ចំនួនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅតាមមជ្ឈមណ្ឌល ............................................ 8
តារាងទី៥៖ ទិន្នន័យធ្វើបច្ចុប្បន្នភាពសិទ្ធិវន្តរបស់ ប.ជ.ស. ក្នុងរយៈពេល១២ខែ ឆ្នាំ២០២១ ...................................11
តារាងទី៦៖ ទិន្នន័យសរុបរបស់សិទ្ធិវន្តដែលធ្វើបច្ចុប្បន្នភាពគិតត្រឹមខែធ្នូ ឆ្នាំ២០២១ ...............................................11
តារាងទី៧៖ ទិន្នន័យសិទ្ធិវន្តនៃ ប.ជ.ស. ដែលកំពុងបើករបបតាមប្រព័ន្ធធនាគារ ក្នុងខែធ្នូ ឆ្នាំ២០២១ .........................11
តារាងទី៨៖ កំណត់ប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារក្នុងរយៈពេល ១២ខែ ឆ្នាំ២០២១ ...................11
តារាងទី៩៖ លុបឈ្មោះអតីតយុទ្ធជនដែលទទួលមរណភាព និងទទួលស្គាល់ជាជនពលី និងមរណៈវិញ ......................11
តារាងទី១០៖ លុបឈ្មោះអតីតយុទ្ធជន និងគ្រួសារចេញពីបញ្ជីបើកប្រាក់ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២១ ................... 12
តារាងទី១១៖ អតីតយុទ្ធជន និងគ្រួសារដែលកំពុងទទួលប្រាក់របបសន្តិសុខសង្គមក្នុងខែធ្នូ ឆ្នាំ២០២១ ...................... 12
តារាងទី១២៖ ស្ថានភាពថវិកាថ្នាក់ជាតិឆ្នាំ២០២១.......................................................................................... 14
តារាងទី១៣៖ ស្ថានភាពថវិកាថ្នាក់មន្ទីររាជធានី ខេត្ត ឆ្នាំ២០២១ ..................................................................... 14
**តារាងឧបសម្ព័ន្ធ៖ ម៉ាទ្រិចស្តីពីការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធី .........................................................**
គ្រួសារក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ ១៩ ទទួលការឧបត្ថម្ភសាច់ប្រាក់ពីកម្មវិធី បែងចែកតាមតំបន់ .23
អតីតមន្ត្រីរាជការស៊ីវិលក្នុងខែធ្នូ ឆ្នាំ២០២១ បែងចែកតាមតំបន់ ........................................................................ 24
អតីតយុទ្ធជនក្នុងខែធ្នូ ឆ្នាំ២០២១ បែងចែកតាមតំបន់......................................................................................25
ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទាតាមតំបន់ និងភេទ ............................................26
កុមារកំព្រា និងកុមារងាយរងគ្រោះដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ បែងចែកតាមតំបន់....................................27

# របាយការណ៍
# បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត

ផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចតុកោណទី១ "ការអភិវឌ្ឍធនធានមនុស្ស" ត្រង់មុំទី៤៖ ការពង្រឹងសមភាពយេនឌ័រ និងកិច្ចគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ បានបង្ហាញយ៉ាងច្បាស់អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការជួយដល់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទក្នុងសង្គម ជាពិសេស កុមារកំព្រា កុមារងាយរងគ្រោះ ស្ត្រី ជនចាស់ជរា ជនពិការ អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល។

ក្នុងគោលបំណងពង្រឹងនូវបណ្តាញសុវត្ថិភាពសង្គម និងកិច្ចគាំពារសង្គម រួមចំណែកក្នុងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន ជាពិសេស ជនរងគ្រោះ និងងាយរងគ្រោះ ឱ្យរួចផុតពីហានិភ័យទាំងឡាយ ក្រសួង ស.អ.យ. បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ ផ្តោតលើកម្មវិធីសំខាន់ៗចំនួនបីគឺ ១.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ២.ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គមនិងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ និង៣.ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ។ អនុកម្មវិធី ១២ រួមមាន ១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះ និងងាយរងគ្រោះ និងកិច្ចការគ្រួសារ ២.ការអភិវឌ្ឍសុខុមាលភាពកុមារនិងយុវនីតិសម្បទា ៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ ៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់ ៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន ៦.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមរាជធានី ខេត្ត ៧.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ៨.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ៩.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ ១០.ការពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ ១១.ការអភិវឌ្ឍធនធានមនុស្ស និង១២.ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូរាជធានី ខេត្ត។

ជាអាទិ៍ ក្នុងឆ្នាំ២០២១នេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាអនុវត្តសម្រេចបានលទ្ធផលដូចខាងក្រោម៖

**I-<u>លទ្ធផលការងារ</u>**

### កម្មវិធីទី១. ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម

### អនុកម្មវិធីទី១.១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ

### ១.១.១.ការងារសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះ និងងាយរងគ្រោះ

-ចាប់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១នេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ការអន្តរាគមក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនប្រជាជនក្រីក្រ និងងាយរងគ្រោះក្នុងកំឡុងប្រយុទ្ធនឹងជំងឺកូវីដ១៩ចំនួន ៦៨២ ៣២៨ គ្រួសារ ដែលបានចំណាយទឹកប្រាក់សរុបចំនួន ២ ០០៤ ៩៥៧ ៧៣៤ ០០០រៀល

-បានផ្តល់ជំនួយសង្គ្រោះបន្ទាន់ជាស្បៀងនិងសម្ភារផ្សេងៗដល់ប្រជាជនរងគ្រោះនិងងាយរងគ្រោះ ៣២ ៨៤១គ្រួសារ

តារាងទី១៖ ជំនួយសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះ និងងាយរងគ្រោះ

| ល.រ | រាជធានី/ខេត្ត | ជំនួយសង្គ្រោះ (គ្រួសារ) |
|---|---|---|
| ១ | ក្រសួង ស.អ.យ. | ២៥៧ |
| ២ | បន្ទាយមានជ័យ | ២ ៩៩២ |
| ៣ | បាត់ដំបង | ១ ២០០ |
| ៤ | កំពង់ចាម | ១ ៦៧៣ |
| ៥ | កំពង់ឆ្នាំង | ៦៣០ |
| ៦ | កំពង់ស្ពឺ | ១ ៥៩៥ |

| | | |
|---|---|---|
| ៧ | កំពត | ២៤០ |
| ៨ | កំពង់ធំ | ៩៦០ |
| ៩ | កណ្តាល | ៧៧០ |
| ១០ | ក្រចេះ | ១ ០៣៧ |
| ១១ | មណ្ឌលគិរី | ១ ១២៦ |
| ១២ | រាជធានីភ្នំពេញ | ៤ ២៤០ |
| ១៣ | ព្រះវិហារ | ១ ២៤០ |
| ១៤ | ព្រៃវែង | ៨៥៣ |
| ១៥ | ពោធិ៍សាត់ | ២៨២ |
| ១៦ | រតនគិរី | ១ ៤២៧ |
| ១៧ | ព្រះសីហនុ | ១ ៥៥៣ |
| ១៨ | សៀមរាប | ១ ៧២០ |
| ១៩ | ស្ទឹងត្រែង | ៩២៤ |
| ២០ | ស្វាយរៀង | ១ ១៣៦ |
| ២១ | តាកែវ | ៣៤០ |
| ២២ | ឧត្តរមានជ័យ | ១ ៣១៨ |
| ២៣ | កែប | ១ ៣៨៦ |
| ២៤ | ប៉ៃលិន | ៦៧៩ |
| ២៥ | កោះកុង | ៦៥០ |
| ២៦ | ត្បូងឃ្មុំ | ៩៦៩ |
| ២៧ | អង្គការ The Filet Relief Agency | ២ ១៤៤ |
| | | ៣២ ៨៤១គ្រួសារ |

**១.១.២.ការងារជនអនាថា**

-បានទទួលជនអនាថា ១ ២៩៥នាក់ ក្នុងនោះ រាជធានីភ្នំពេញ ១ ២៦៧នាក់ ខេត្តបន្ទាយមានជ័យ ២១នាក់ កំពង់ស្ពឺ ១នាក់ និងខេត្តរតនគិរី ៦នាក់ មកពិគ្រោះយោបល់ អប់រំ និងបញ្ជូនទៅទទួលសេវាបន្តនៅមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ និងមណ្ឌលរបស់អង្គការដៃគូ និងបានបញ្ជូនត្រឡប់ទៅសហគមន៍វិញ ៥៤១នាក់ ក្នុងនោះ រាជធានីភ្នំពេញ ៥១១នាក់ ខេត្តរតនគិរី ០៦នាក់ កំពង់ចាម ២២នាក់ កំពង់ស្ពឺ ០១នាក់ និងខេត្តកែប ០១នាក់

-មជ្ឈមណ្ឌលជនវិបល្លាសស្មារតីស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បានទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅចំនួន ៧០នាក់ និងបានធ្វើសមាហរណកម្មទៅគ្រួសារវិញចំនួន ០៤នាក់

-បានរៀបចំសេចក្តីព្រាង ស្តីពីគោលការណ៍ណែនាំជួយជនវិបល្លាសស្មារតី

-បានពិនិត្យ និងកែសម្រួលផែនការយុទ្ធសាស្ត្រជាតិ ស្តីពីកម្លាំងសេវាសង្គមនៅកម្ពុជា ២០២២-២០៣១។

**១.១.៣.ការទប់ស្កាត់ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ**

បានចុះសួរសុខទុក្ខ និងនាំយកអំណោយជូនជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងរងផលប៉ះពាល់ដោយមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗ ចំនួន ៣៣១នាក់ ខេត្តកែប ១៦២នាក់ និងខេត្តកំពង់ធំ ១៦៩នាក់។

**១.១.៤.ការងារគ្រួសារ និងយេនឌ័រ**

-បានរៀបចំពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១១០ ទិវានារីអន្តរជាតិ ៨មីនា ឆ្នាំ២០២១ ដែលមានអ្នកចូលរួមចំនួន ៥៧០នាក់

-បានចុះត្រួតពិនិត្យតាមដានភាពមិនប្រក្រតីរបស់មន្ត្រីអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារក្រោម ០២ឆ្នាំ នៅខេត្តព្រះសីហនុ

-គិតពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩ ដល់ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២១ រដ្ឋាភិបាលបានផ្តល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុ០-២ឆ្នាំ សរុបចំនួន ២៤៤ ៦៣៦នាក់ ដែលបានចំណាយថវិកាសរុបចំនួន ៦១ ៧៧៦ ៩៦០ ០០០៛។ ដោយឡែកសម្រាប់១១ខែ ឆ្នាំ២០២១នេះ រាជរដ្ឋាភិបាលបានផ្តល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុ០-២ឆ្នាំ សរុបចំនួន ៤២ ៧៣៩នាក់ ចំណាយថវិកាអស់ ២៤ ៩៦៥ ៣២៨ ០០០៛

តារាងទី២៖ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ០២ឆ្នាំ ដែលទទួលបានប្រាក់ឧបត្ថម្ភកម្មវិធី ក្នុងឆ្នាំ២០២១

| លរ | រាជធានី ខេត្ត | អ្នកទទួលផល (នាក់) | | | ចំនួនស្ត្រី កុមារ និងសម្រាល មកអនុវត្តលក្ខខណ្ឌ[1] | ថវិកា (៛) |
|---|---|---|---|---|---|---|
| | | ស្ត្រី | កុមារ | ចំនួនសម្រាល | ចំនួនលក្ខខណ្ឌ | |
| ១ | បន្ទាយមានជ័យ | ២ ០៦០ | ២១២ | ៣៧៩ | ២៣ ០៨០ | ១ ៤០២ ៨៤០ ០០០ |
| ២ | បាត់ដំបង | ៦ ២៦៩ | ៧០០ | ៩០០ | ៦២ ៣៨៩ | ៣ ៨៥២ ៤០០ ០០០ |
| ៣ | កំពង់ចាម | ១ ៩៦៥ | ២០៩ | ៣៧៨ | ២១ ៣២០ | ១ ៣៦៤ ៩៦០ ០០០ |
| ៤ | កំពង់ឆ្នាំង | ១ ៣៨៩ | ១៤៥ | ២៦២ | ១៣ ៦២៧ | ៨៨៣ ៣២០ ០០០ |
| ៥ | កំពង់ស្ពឺ | ៦៧៧ | ១៧៣ | ២៧២ | ៨ ៣២១ | ៥៥២ ៤៤០ ០០០ |
| ៦ | កំពង់ធំ | ២ ៣៦៥ | ២២៣ | ៣៤៨ | ១៩ ៩០២ | ១ ២៨៤ ៧២០ ០០០ |
| ៧ | កំពត | ១ ៥៧២ | ១៣៣ | ២៤៩ | ១៤ ៤១៨ | ៩២៩ ១២០ ០០០ |
| ៨ | កណ្ដាល | ១ ៤៧៦ | ៣៤០ | ៦០០ | ១៨ ៩០៩ | ១ ១៨៩ ០០០ ០០០ |
| ៩ | កោះកុង | ៥០៤ | ៧៧ | ៧៤ | ៣ ៣៩៤ | ២៤៩ ១៦០ ០០០ |
| ១០ | ក្រចេះ | ២ ១៨១ | ៣៣៩ | ៥៥៤ | ២០ ៧៣៨ | ១ ៣៦៦ ២៤០ ០០០ |
| ១១ | មណ្ឌលគិរី | ៣២៩ | ៥៥ | ៩៣ | ៣ ៣១០ | ២១៩ ៩៦០ ០០០ |
| ១២ | ភ្នំពេញ | ១១ ២០ | ៣៩១ | ៨១៩ | ១៣ ២៤២ | ១ ២៥៨ ៨៨០ ០០០ |
| ១៣ | ព្រះវិហារ | ១ ៣៥០ | ១៦២ | ២៣៦ | ១៣ ៥៦៣ | ៨៦៣ ៣២០ ០០០ |
| ១៤ | ព្រៃវែង | ១ ៩៨៧ | ២៨០ | ៥៣៦ | ២៣ ៣៤៦ | ១ ៤៦៨ ០៤០ ០០០ |
| ១៥ | ពោធិ៍សាត់ | ១ ៥០១ | ១៨៥ | ២២៨ | ១៥ ៣៧៩ | ៩៦៧ ០៨០ ០០០ |
| ១៦ | រតនគិរី | ៨២២ | ៨៥ | ១៥២ | ៧ ១៩៦ | ៤៦១ ៧២៨ ០០០ |
| ១៧ | សៀមរាប | ៣ ២៨០ | ៣៥៣ | ២៧៨ | ២៧ ៦២៩ | ១ ៦៣៥ ៨៤០ ០០០ |
| ១៨ | ព្រះសីហនុ | ៤៥៤ | ៨៧ | ២ ០១១ | ៤ ៤២១ | ៦៧៩ ៤០០ ០០០ |
| ១៩ | ស្ទឹងត្រែង | ៧៧៤ | ៦៨ | ១៥០ | ៦ ០២៣ | ៤០៨ ៧៦០ ០០០ |
| ២០ | ស្វាយរៀង | ៧១២ | ១០៥ | ១៩៩ | ៨ ០១៨ | ៥១៤ ៦៤០ ០០០ |
| ២១ | តាកែវ | ១ ៤៩៧ | ២១៣ | ៣៦៣ | ១ ៧ ៥៣៧ | ១ ១១៦ ៥៦០ ០០០ |
| ២២ | ឧត្តរមានជ័យ | ៨៧៧ | ១០៣ | ១៦៦ | ៩ ៩៤៤ | ៦០២ ៣២០ ០០០ |
| ២៣ | កែប | ៩២ | ១៤ | ១២ | ៨៥១ | ៥៣ ៣២០ ០០០ |
| ២៤ | ប៉ៃលិន | ៣៩៦ | ៤៥ | ១១៨ | ៤ ៧៣៧ | ២៩៥ ០៤០ ០០០ |
| ២៥ | ត្បូងឃ្មុំ | ២ ០៧៧ | ១១៦ | ៣៦៥ | ២ ២៣៤ | ១ ៣៤៦ ២៤០ ០០០ |
| **សរុប** | | **៣៧ ៨២៦** | **៤ ៩១៣** | **៩ ៧៤២** | **៣៨៣ ៦២៨** | **២៤ ៩៦៥ ៣២៨ ០០០** |

**១.១.៥.ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការធ្វើសមាហរណកម្មជនរងគ្រោះ**

-បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទដែលត្រូវបានធ្វើមាតុភូមិវត្តន៍ និងទទួលពីប្រទេសនានាសរុបចំនួន ៤០៤នាក់ ស្រី៣៦០នាក់ មកពីប្រទេសចិន ៣១៧នាក់ វៀតណាម ១៤នាក់ ឥណ្ឌូនេស៊ី ០១នាក់ ម៉ាឡេស៊ី ៣៤នាក់ ថៃ ៣៤ និងសិង្ហបុរី ០៤នាក់ និងបានធ្វើសមាហរណកម្មត្រឡប់ទៅសហគមន៍វិញចំនួន ៣១៧នាក់

-បានទទួលពលករចំណាកស្រុកពីប្រទេសថៃ ៧៣ ១៨៦នាក់ ស្រី ៣២ ៦០៨នាក់ និងបានធ្វើការសម្ភាសដើម្បីកំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះ និងបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ

1 សំដៅដល់ចំនួនដងនៃការពិនិត្យសុខភាពរបស់អ្នកទទួលផលតាមដំណាក់កាលនីមួយៗ)

-បានធ្វើមាតុភូមិនិវត្តស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សជាជនជាតិវៀតណាមចំនួន ០៥នាក់ ទៅប្រទេសកំណើតវិញ

-បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សសរុបចំនួន ១ ៨០៨នាក់ ស្រី ១ ០៣៥នាក់ និងបានបញ្ជូនទៅស្តារនីតិសម្បទានៅមជ្ឈមណ្ឌលរបស់អង្គការដៃគូ

-បានបន្តតាមដានចំនួន ៥៧នាក់ និងបិទករណីចំនួន ៨០នាក់

-បានចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលមានកិច្ចព្រមព្រៀងជាមួយក្រសួង ស.អ.យ. ចំនួន ១៧មណ្ឌល ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង និងខេត្តបន្ទាយមានជ័យ

-បានរៀបចំសិក្ខាសាលា ស្តីពីគោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះ និងគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្របដល់មន្ត្រី ស.អ.យ. ក្រុងស្រុក ខេត្ត មេឃុំ មេភូមិ មន្ត្រី គ.ក.ន.ក. គ្រូបង្រៀន គ្រូពេទ្យ ប៉ូលីសប៉ុស្តិ៍នៃខេត្តស្វាយរៀង ព្រៃវែង និងខេត្តកំពង់ចាមចំនួន ៧វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ២៨៦នាក់។

**អនុកម្មវិធីទី១.២.ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា**

**១.២.១.ការងារមជ្ឈមណ្ឌលកុមារកំព្រា និងការថែទាំកុមារ**

-គិតមកដល់ខែវិច្ឆិកា ឆ្នាំ២០២១នេះ មណ្ឌលថែទាំកុមារមានចំនួន១៩៩មណ្ឌល មានកុមារសរុបចំនួន ៥ ៤៤០នាក់ កុមារីចំនួន ២ ៥៦៩នាក់ និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ចំនួន ១ ៧១៦នាក់ ស្រី៨៨៧នាក់ ក្នុងនោះមណ្ឌលថែទាំដែលគ្រប់គ្រងនិងគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល មានចំនួន ១៧៨មណ្ឌល មានកុមារចំនួន ៤ ៧៣៤នាក់ កុមារីចំនួន ២ ២៧៩នាក់ និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ចំនួន ១ ៣៩០នាក់ ស្រីចំនួន ៧២២នាក់ មណ្ឌលថែទាំរបស់រដ្ឋមានចំនួន២១ មានកុមារចំនួន ៧០៨នាក់ កុមារីចំនួន ២៩០នាក់ និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ចំនួន ៣២៦នាក់ ស្រី ១៦៥នាក់។ កន្លែងថែទាំបែបសហគមន៍មានចំនួន ១០១កន្លែង មានកុមារចំនួន ២ ១៨៦នាក់ កុមារីចំនួន ១ ០៤៧នាក់ និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ចំនួន៥២១នាក់ ស្រីចំនួន ២៧២នាក់។ មណ្ឌលកុមារកំព្រាមួយចំនួនទទួលការឧបត្ថម្ភបន្ថែមពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ក្នុងនោះ៖

តារាងទី៣៖ ការឧបត្ថម្ភរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជូនមណ្ឌលកុមារកំព្រា

| ល.រ | ឈ្មោះមណ្ឌល/អង្គការ | ការឧបត្ថម្ភ | | |
|---|---|---|---|---|
| | | អង្ករ | ថវិកា | សម្ភារ |
| ១ | បុរីទារក និងកុមារជាតិ | ២តោន/ឆ្នាំ | ១០លានរៀល/ឆ្នាំ | គ្រឿងបរិភោគ/ឆ្នាំ |
| ២ | មណ្ឌលសាលាគថ្លង់ភ្នំពេញថ្មី | ១តោន/ខែ | ៣លានរៀល/ខែ | |
| ៣ | មណ្ឌលសាលាគថ្លង់ច្បារអំពៅ | ១តោន/ខែ | ៣លានរៀល/ខែ | |
| ៤ | មណ្ឌលកុមារកំព្រាភ្នំពេញថ្មី | ៥០០គីឡូក្រាម/ខែ | ១លានរៀល/ខែ | |
| ៥ | មជ្ឈមណ្ឌលកូលាបទី៤ | | ៣លានរៀល/ខែ | |
| ៦ | មណ្ឌលផ្កាម្លិះ | ១តោន/ខែ | ៣លានរៀល/ខែ | |
| ៧ | សមាគមជនគ្មានទីពឹង | ១តោន/ខែ | ៣លានរៀល/ខែ | |
| ៨ | បុរីកុមារមិត្តភាពកម្ពុជាបារាំងហុងគ្រី | | ១,៩លានរៀល/ខែ | |

-ដោយឡែក សម្រាប់បុរីទារកនិងកុមារជាតិ ក្រៅពីអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** បានឧបត្ថម្ភ ១០ ០០០ដុល្លារអាម៉េរិក/ខែ គិតចាប់ពីខែមីនា ឆ្នាំ២០១៩ រហូតដល់ខែឧសភា ឆ្នាំ២០២១ និងចាប់ពីខែមិថុនា បានបន្តឧបត្ថម្ភ ៥ ០០០ដុល្លារអាម៉េរិក/ខែ។

**១.២.២.ការងារថែទាំជំនួសចំពោះកុមារ និងអធិការកិច្ច**

-បានចុះពិនិត្យ និងវាយតម្លៃទទួលស្គាល់មណ្ឌលថែទាំកុមាររបស់អង្គការ ដូចជា មណ្ឌលកុមារកំព្រាដេវីដខេត្តឧត្តរមានជ័យ មណ្ឌលកុមារអភិវឌ្ឍន៍ថ្មីខេត្តកំពង់ឆ្នាំង មណ្ឌលកុមារកំព្រាដៃលម៉ុនកម្ពុជាខេត្តបន្ទាយមានជ័យ មណ្ឌលស្នាក់នៅបណ្តោះអាសន្នខេត្តព្រះសីហនុ សហគមន៍អូរព័ន្ធខេត្តតាកែវ និងមណ្ឌលកុមារសន្តិភាពខេត្តបាត់ដំបង

-បានផ្តល់វិញ្ញាបនប័ត្រ ទទួលស្គាល់មណ្ឌលថែទាំកុមារ ចំនួន ០៦អង្គការ ស្មើនឹង ០៧មណ្ឌល

-បានចេញប្រកាស ស្តីពីនីតិវិធីការអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌

-ដោយមានគាំទ្រពីអង្គការយូនីសេហ្វ ក្រសួង ស.អ.យ. បានចែកថាប្លែតជូនមន្ត្រីការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមនៃក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្ត សរុបចំនួន ២០៤គ្រឿង និងកុំព្យូទ័រយួរដៃចំនួន ២៥គ្រឿង ដល់មន្ត្រីបង្គោលនៃមន្ទីរ ស.អ.យ. រាជធានី ខេត្ត

-បានទទួលគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងករណី Primero[2] និងបើកវគ្គរំលឹកអំពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាក្នុងការធ្វើអធិការកិច្ចកន្លែងថែទាំកុមារ ដល់មន្ត្រីបង្គោលនៃមន្ទីរ ស.អ.យ. រាជធានី ខេត្ត ព្រមទាំងបានផ្ទៀងផ្ទាត់ទិន្នន័យដែលបានធ្វើអធិការកិច្ចរួច

-បានបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងករណីតាមប្រព័ន្ធបច្ចេកវិទ្យា Primero ដល់មន្ត្រីបង្គោលនៃមន្ទីរ ស.អ.យ. បុគ្គលិកសង្គម មន្ត្រីការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម នៅទូទាំង ២៥ រាជធានីខេត្ត ដែលមានអ្នកចូលរួមចំនួន ២០៤នាក់

-បានផ្សព្វផ្សាយរបាយការណ៍ ស្តីពីការអនុវត្តល្អក្នុងការរៀបចំកម្មវិធីថែរក្សាកុមារក្នុងគ្រួសារ និងការបង្ការការបំបែកកុមារពីគ្រួសារក្នុងប្រទេសកម្ពុជា និងរបាយការណ៍ ស្តីពីការអនុវត្តផែនការសកម្មភាពដើម្បីធ្វើឱ្យប្រសើរឡើងនូវការថែទាំកុមារ និងសមាហរណកម្មកុមារចំនួន ៣០% ពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសាររបស់ពួកគេវិញដោយសុវត្ថិភាព

-បានពិនិត្យ និងកែសម្រួលសេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការធ្វើសមាហរណកម្មកុមារ ការបង្វែរកន្លែងថែទាំ (ជាលក្ខណៈមណ្ឌល) និងការបិទកន្លែងថែទាំកុមារ

-បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំផែនការប្រតិបត្តិការថ្នាក់ខេត្ត ស្តីពីកិច្ចការពារកុមារនៅរាជធានីភ្នំពេញ ខេត្តព្រៃវែង ក្រចេះ បាត់ដំបង កណ្តាល ព្រះសីហនុ សៀមរាប រតនគីរី កំពត និងខេត្តបន្ទាយមានជ័យ ដោយមានការដឹកនាំ និងសម្របសម្រួល ពិគ្រោះយោបល់ពីគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

-បានសម្របសម្រួលដឹកនាំការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារឆ្នាំ២០១៧-២០២១

-បានរៀបចំសិក្ខាសាលា ស្តីពីការចុះស្រង់ទិន្នន័យ និងការប៉ានប្រមាណកុមារដែលត្រូវធ្វើផែនការអចិន្ត្រៃយ៍ ជាមួយមន្ត្រីមន្ទីរ ស.អ.យ. រាជធានីភ្នំពេញ

-បានពិនិត្យ និងកែសម្រួលសេចក្តីព្រាងទម្រង់ និងបែបបទនៃការទទួលស្គាល់ឪពុកម្តាយធម៌

-បានផ្សព្វផ្សាយយុទ្ធនាការ "គ្រួសាររឹងមាំ" ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ តាមរយៈ៖

- ការផលិតវីដេអូខ្លីសរុបចំនួន ០៦ប្រធានបទ ដើម្បីផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង និងឆ្លើយតបអំពើហិង្សាលើកុមារ
- ការរៀបចំសៀវភៅណែនាំសម្រាប់គ្រូបង្គោលផ្សព្វផ្សាយតាមសហគមន៍ស្តីពីគ្រួសាររឹងមាំ
- ការផលិតអត្ថបទនិងរូបភាពសម្រាប់ផ្សព្វផ្សាយលើបណ្តាញសង្គម facebook ចំនួន ១៧២ដង ក្នុងនោះមានវីដេអូចំនួន ៤២ ដែលមានអ្នកចូលមើលចំនួន ៧ ៣១១ ៨៥០នាក់
- ការផ្សាយផ្ទាល់នៃកម្មវិធីជជែកពិភាក្សា និងចាក់ល្ខោននិយាយរបស់យុទ្ធនាការគ្រួសាររឹងមាំចំនួន ៥រឿង "១. ខ្ញុំជាកូនម៉ែ ២.ព្រោះអ្វី ៣.ចាកកាយក្លាយទុក្ខ ៤.សន្យាអប្រិយ និង៥.អម្រែកគ្រួសារ" សរុបចំនួន ២៥ភាគ
- ការចាក់ផ្សាយវីដេអូរអប់រំខ្លីចំនួន ២ ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ នៅប៉ុស្តិ៍ CTN និង MyTV
- ការសហការជាមួយ គ.ក.ស.ក. រៀបចំពិធីបើកយុទ្ធនាការគ្រួសាររឹងមាំ ក្នុងខេត្តរតនគីរី ដែលមានអ្នកចូលរួមសរុបចំនួន ៩៥នាក់

-បានសិក្សាវាយតម្លៃនៃការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ២០១៧-២០២១ និងបានពិនិត្យ កែសម្រួលរបាយការណ៍សិក្សាវាយតម្លៃនេះ

-បានរៀបចំសៀវភៅមេរៀនសម្រាប់ការបណ្តុះបណ្តាលអំពីយុទ្ធសាស្ត្រទាំង ៧ INSPIRE (I : Implementation and enforcement of laws; N : Norms and values; S : Safe environments; P : Parent and caregiver support; I : Income and economic strengthening; R : Response and support services; and E : Education and life

2 គឺជាឈ្មោះប្រព័ន្ធពត៌មានវិទ្យាគ្រប់គ្រងទិន្នន័យ ស្តីពីការគ្រប់គ្រងករណីកុមារ

skills) និងបានបណ្តុះបណ្តាលតាមអនឡាញចំនួន ៥វគ្គ ដល់អ្នកពាក់ព័ន្ធនៃខេត្តបាត់ដំបង សៀមរាប កណ្តាល ព្រះសីហនុ និងរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមសរុប ៣៧៤នាក់

-បានរៀបចំកិច្ចប្រជុំពិភាក្សាគោលនយោបាយថ្នាក់ជាតិ ស្តីពីការស្វែងរកដំណោះស្រាយបញ្ចប់អំពើហិង្សាលើកុមារតាមរយៈប្រព័ន្ធអនឡាញ ដែលមានអ្នកចូលរួម ២២០នាក់

-បានសហការជាមួយអង្គការ Holt International អនុវត្តសាកល្បងកម្មវិធីសុំកូនក្នុងប្រទេស។ ជាលទ្ធផល បានរៀបចំសេចក្តីព្រាងសៀវភៅណែនាំអំពីជំហាននៃការអនុវត្តការងារសុំកូនក្នុងប្រទេស កុមារចំនួន ៥នាក់ ត្រូវបានតុលាការខេត្តបាត់ដំបងចេញដីការសម្រេចអំពីការបង្កើតការសុំកូនពេញលេញ។ ក្រសួងបានទទួលដីការលេខ៦០៧ "ជ".ដ.ម ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ ក្នុងសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខៈ ៥៨៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ សម្រេចជ្រើសតាំងប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនចំនួន ២៨នាក់ ដែលកំពុងស្នាក់នៅមណ្ឌលបុរីទារក និងកុមារជាតិ

-បានពិនិត្យ និងកែសម្រួលសេចក្តីព្រាងប្រកាស ស្តីពីនីតិវិធីអនុវត្តសុំកូនក្នុងប្រទេស

-បានប្រកាសផ្សព្វផ្សាយជូនដំណឹងជាសាធារណៈ ស្តីពីការប្រកាសស្វែងរកឪពុកម្តាយចិញ្ចឹមក្នុងប្រទេស ឬអាណាព្យាបាលស្របច្បាប់សម្រាប់អនីតិជន ២៥នាក់ ដែលកំពុងស្នាក់នៅក្នុងបុរីទារក និងកុមារជាតិ

-បានចុះស្វែងរកគ្រួសារកំណើតរបស់កុមារចំនួន ៦នាក់ ក្នុងរាជធានីភ្នំពេញ ខណ្ឌទួលគោក ខណ្ឌមានជ័យ និងខណ្ឌដូនពេញ ដែលកំពុងស្នាក់នៅក្នុងបុរីទារក និងកុមារជាតិ ដើម្បីរៀបចំផែនការអេចិន្ត្រៃយ៍ ជាលទ្ធផលកុមារចំនួន ០៤នាក់ រកមិនឃើញឪពុកម្តាយបង្កើត ០១នាក់កំពុងស្វែងរកដោយបុគ្គលិកសង្គមកិច្ចខណ្ឌមានជ័យ និង០១នាក់ទៀត មានគ្រួសារសាច់ញាតិ

-បុរីទារក និងកុមារជាតិ បាននឹងកំពុងទទួលចិញ្ចឹមកុមារសរុបចំនួន ១៤៧នាក់ ស្រី ៦៩នាក់ ក្នុងនោះ កុមារពិការ ១២៦នាក់ កុមារផ្ទុកមេរោគអេដស៍ ១២នាក់ និងកុមារធម្មតា ០៩នាក់។ កុមារ និងយុវជនពិការ(ខ្សោយសតិបញ្ញា)ចំនួន ១២នាក់ ស្រី ៦នាក់ បានចូលរៀនថ្នាក់អប់រំពិសេស និងរៀនវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជាមួយយុវជន និងយុវនារីមកពីសហគមន៍នៅអង្គការសាលាទន្សាយ។

### ១.២.៣ ការងារសុំកូនអន្តរប្រទេស

-បានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យនូវសំណុំឯកសារចាស់ៗនៃការសុំកូនអន្តរប្រទេសចំនួន ២៣០ករណី

-បានទទួលរបាយការណ៍ស្តីពីការវិវឌ្ឍរបស់កូនសុំ ៣៤៣ករណី មកពីប្រទេសអ៊ីតាលីចំនួន ៣២៧ករណី អូទ្រីស ១៣ករណី និងម៉ាល់តា ០៣ករណី។ តាមការវាយតម្លៃ ស្ថានភាពកូនមានលក្ខណៈល្អប្រសើរទាំងផ្នែកសុខភាព ការរស់នៅ និងសិក្សារៀនសូត្រ។

### ១.២.៤ ការងារក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.)

-បានរៀបចំប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ "ផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារឆ្នាំ២០២១-២០២៥" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមរយៈប្រព័ន្ធហ្សូមដែលមានអ្នកចូលរួមចំនួន ៦០០នាក់

-បានរៀបចំប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ "ផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ ២០១៩-២០២៩" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច តាមរយៈប្រព័ន្ធហ្សូម

-បានរៀបចំផែនការសកម្មភាព ២០២១-២០២៥ ផែនការអភិវឌ្ឍន៍ធនធានមនុស្ស និងថវិកានិងផែនការត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ

-បានរៀបចំសិក្ខាសាលាស្តីពីការលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ នៅខេត្តសៀមរាប រតនគិរី និងខេត្តស្ទឹងត្រែង ក្នុងគោលបំណងជំរុញការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ការកំណត់រកដំណោះស្រាយជាយុទ្ធសាស្ត្រ និងឱកាសនៃកិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធ ដែលមានសមាសភាពអ្នកចូលរួមសរុបចំនួន ៤០៧នាក់ ស្រីចំនួន ២៥០នាក់

-បានសម្របសម្រួលរៀបចំកិច្ចពិភាក្សាតុមូល និងកិច្ចពិភាក្សាតាមវិទ្យុ នៅស្ថានីយ៍វិទ្យុ និងទូរទស្សន៍បាយ័ន្ត ក្រោមប្រធានបទ "១.ការលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិស្ដីពីប្រព័ន្ធកិច្ចការពារកុមារ និង២.ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីធឺណែត"

-បានរៀបចំកិច្ចប្រជុំត្រៀមសម្រាប់គណៈប្រតិភូអន្តរក្រសួងចូលរួមកិច្ចប្រជុំលើកទី៨៧ ដើម្បីការពាររបាយការណ៍ជាតិលើកទី៤ ទី៥ និងទី៦ ស្ដីពីការអនុវត្តអនុសញ្ញា ស្ដីពីសិទ្ធិកុមារ

-បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុស្ត្រី ១០២.៥ ក្រោមប្រធានបទ "អំពើហិង្សាលើស្ត្រី និងកុមារ"

-បានរៀបចំកិច្ចពិភាក្សាតាមប្រព័ន្ធហ្សូម ស្ដីពីការលើកម្ពស់ការអនុវត្តផែនការការអនុវត្តគោលនយោបាយជាតិ ស្ដីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩- ២០២៩ នៅស្ថានីយ៍វិទ្យុ FM 102 Mhz

-បានចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធីគ្រួសាររឹងមាំ ក្រោមប្រធានបទ "ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ" និងល្ខោននិយាយរឿង «សន្យាអប្រិយ» ផ្សាយតាមវិទ្យុដូនពេញ FM 87.5 Mhz និងវិទ្យុទន្លេ FM 102.5 Mhz

-បានរៀបចំរបាយការណ៍វឌ្ឍនភាពរយៈពេល ៥ឆ្នាំ ២០១៧-២០២១ ក្នុងកិច្ចការពារសិទ្ធិស្ត្រី និងការលើកកម្ពស់សមភាពយេនឌ័រ របស់ អគ្គលេខាធិការដ្ឋាន ក.ជ.ក.

-បានរៀបចំសិក្ខាសាលា ស្ដីពីការលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិ ស្ដីពីប្រព័ន្ធការពារកុមារ ឆ្នាំ២០១៩-២០២៩ និងផែនការអនុវត្តគោលនយោបាយជាតិ ស្ដីពីប្រព័ន្ធកិច្ចការពារកុមារ នៅសណ្ឋាគារភ្នំពេញ ដែលមានអ្នកចូលរួមសរុបចំនួន ៧០នាក់ ស្រី ២៣នាក់

-បានរៀបចំវគ្គបណ្ដុះបណ្ដាល ស្ដីពីសុវត្ថិភាពនៃការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងសង្គមដល់សមាជិកគណៈកម្មការការការពារកុមារថ្នាក់ជាតិ និងក្រុមការងារបច្ចេកទេសអន្តរក្រសួង OCSE (Online Child Sexual Exploitation) នៅមន្ទីរ ស.អ.យ. ខេត្តកែប ដែលមានអ្នកចូលរួមសរុបចំនួន ៦០នាក់ ស្រី ១៨នាក់

-បានសហការជាមួយអង្គការ Hagar សម្របសម្រួលរៀបចំសិក្ខាសាលា ស្ដីពីសិទ្ធិកុមារ កិច្ចការពារកុមារ និងច្បាប់នានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស នៅសាលាខេត្តកំពង់ធំ ដែលមានអ្នកចូលរួមសរុបចំនួន ៥២នាក់ ស្រី៤០នាក់។

### ១.២.៥.ការងារយុវនីតិសម្បទា

### ១.២.៥.១.ការអប់រំ ទប់ស្កាត់កុមារ យុវជនប្រព្រឹត្តបទល្មើស និងសេពគ្រឿងញៀន

-បានធ្វើបច្ចុប្បន្នភាពអនីតិជនទំនាស់នឹងច្បាប់នៅតាមពន្ធនាគារ និងមណ្ឌលអប់រំកែប្រែតាមរាជធានី ខេត្ត មានអនីតិជនសរុបចំនួន ១ ៤០៤នាក់ ស្រី ៦០នាក់

-បានសហការជាមួយអង្គការសម្ព័ន្ធមេត្រីភាពពន្ធនាគារ ផ្ដល់សេវាគាំទ្រផ្នែកសម្ភារសិក្សា សុខភាព និងសុវត្ថិភាពដល់កូនជនជាប់ឃុំសរុប ៩០២នាក់ ស្រី ៤២៧នាក់

-បានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការមណ្ឌលយុវនីតិសម្បទា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។

### ១.២.៥.២.ការស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

-បានកែសម្រួលសេចក្ដីព្រាងប្រកាសអន្តរក្រសួងស្ដីពី បែបបទ និងនីតិវិធីការផ្ទេរ ប្រគល់ទទួលការគ្រប់គ្រង បញ្ជីឈ្មោះ និងនីតិវិធីដោយឡែកការរៀបចំ ចំណាត់ថ្នាក់សន្តិសុខទណ្ឌិត និងអនីតិជនជាប់ឃុំនៅក្នុងមណ្ឌលយុវនីតិសម្បទា

-បានរៀបចំសេចក្ដីព្រាងប្រកាស ស្ដីពីលក្ខខណ្ឌអប្បបរមានៃការស្ដារនីតិសម្បទា ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងសមាហរណកម្មអ្នកញៀនគ្រឿងញៀននៅក្នុងមជ្ឈមណ្ឌលព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

-បានបើកវគ្គបណ្ដុះបណ្ដាល ស្ដីពីការប្រើប្រាស់ទម្រង់របាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនទំនាស់នឹងច្បាប់ចំនួន ២វគ្គ នៅខេត្តបាត់ដំបង និងខេត្តកំពត

-ភ្នាក់ងារសង្គមកិច្ចខេត្តកំពង់ចាមបានចុះតាមដាន និងសួរសុខទុក្ខអនីតិជនចំនួន ៤នាក់ ដែលទទួលដីការបង្វែរឱ្យទៅរស់នៅសហគមន៍ស្រុកកំពង់សៀម និងក្រុងកំពង់ចាម

-បានរៀបចំសេចក្តីប្រកាសអន្តរក្រសួង រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មហាផ្ទៃ និងក្រសួងយុត្តិធម៌ ស្តីពីបែបបទ និងនីតិវិធីនៃការផ្ទេរ ប្រគល់ ទទួលគ្រប់គ្រង និងស្តារនីតិសម្បទាអនីតិជនទំនាស់និងច្បាប់

-បានចេញប្រកាសបញ្ចូលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ៦ ០២០នាក់ ស្រី ២៤៦នាក់ និងចេញប្រកាសបញ្ចេញជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ៦ ៩៧០នាក់ ស្រី ២៥៧នាក់ ដូចនេះ នៅសល់ជាក់ស្តែងចំនួន ២ ៩៩៨នាក់ ស្រី ១៥០នាក់

-បានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដល់ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនចំនួន ៧២៥នាក់ ស្រី ៩៧នាក់ មានជំនាញកាត់ដេរ សម្អាងការ កំព្យូទ័រ កាត់សក់ ភាសាអង់គ្លេស ជួសជុលម៉ាញ៉េ និងបោះពុម្ពរូបភាពលើអាវ។ ក្រៅពីនេះ មជ្ឈមណ្ឌលមានកម្មវិធីអក្ខរកម្ម កម្មវិធីកីឡា និងដាំដំណាំផងដែរ

តារាងទី៤ ៖ ចំនួនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅតាមមជ្ឈមណ្ឌល

| លរ | មជ្ឈមណ្ឌល | សល់ក្នុងឆ្នាំ២០២០ | | បញ្ចូលក្នុងឆ្នាំ២០២១ | | បញ្ចេញក្នុងឆ្នាំ២០២១ | | សល់ជាក់ស្តែងចុងឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរាជធានីភ្នំពេញ | ២៨៨ | ១០ | ៥៧២ | ៩ | ៦២០ | ១៤ | ២៤០ | ៥ |
| ២ | មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀនខេត្តព្រះសីហនុ | ០០ | ០០ | ២២៤ | ០០ | ១៣៥ | ០០ | ៨៩ | ០០ |
| ៣ | ជីវិតថ្មីភ្នំបាក់ខេត្តបន្ទាយមានជ័យ | ៦៧៦ | ៣៨ | ៩៨៣ | ៤៨ | ៩៣៩ | ៦៧ | ៧២០ | ១៩ |
| ៤ | ឱកាសខ្ញុំរាជធានីភ្នំពេញ | ២ ១៩៨ | ១០៣ | ២ ៦៦៩ | ១៧៥ | ៣ ៤៨០ | ១៦៤ | ១ ៣៨៦ | ១១៤ |
| ៥ | ពិភពនៃក្តីសង្ឃឹមខេត្តបាត់ដំបង | ៣០៥ | ០០ | ៤៤១ | ៧ | ៤៥៩ | ២ | ២៨៧ | ៥ |
| ៦ | កងរាជអាវុធហត្ថខេត្តបាត់ដំបង | ៨១ | ០០ | ១៦ | ០០ | ៩៧ | ០០ | ០០ | ០០ |
| ៧ | បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| ៨ | ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនខេត្តសៀមរាប | ៤០០ | ១០ | ១ ១១៦ | ៧ | ១ ២៤០ | ១០ | ២៧៦ | ៧ |
| ៩ | បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តព្រះសីហនុ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| | សរុប | ៣ ៩៤៨ | ១៦១ | ៦ ០២០ | ២៤៦ | ៦ ៩៧០ | ២៥៧ | ២ ៩៩៨ | ១៥០ |

**អនុកម្មវិធីទី១.៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ**

-បានរៀបចំពិធីចែកអំណោយដ៏ថ្លៃថ្លារបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ចែកជូនដល់សមាគមមន្ត្រីជនពិការ និងបងប្អូនជនពិការរស់នៅក្នុងអង្គការ PPCIL

-បានរៀបចំកិច្ចប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការវិសោធនកម្មច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ

-បានអប់រំ ផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងអំពីច្បាប់ និងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ២០១៩-២០២៣ ដល់អង្គការ សង្គមស៊ីវិលតំណាងជនមានពិការភាព ២៥ រាជធានី ខេត្ត តាមរយៈកិច្ចប្រជុំចំនួន ៣០ដង

-បានផ្សព្វផ្សាយដាក់ឱ្យអនុវត្តប្រកាសអន្តរក្រសួង ស្តីពីលក្ខខណ្ឌនៃការចេញប័ណ្ណបើកបរសម្រាប់ជនមានពិការភាព

-បានរៀបចំវគ្គបណ្តុះបណ្តាលណែនាំស្តីពីវិធីសាស្ត្រទាក់ទង និងលក្ខខណ្ឌនានាសម្រាប់ការអភិវឌ្ឍពិការភាពប្រកបដោយបរិយាបន្ន

-បានរៀបចំសិក្ខាសាលា ស្តីពីការឆ្លុះបញ្ចាំងវឌ្ឍនភាពក្រុមប្រឹក្សាសកម្មភាពជនពិការខេត្តគោលដៅចំនួន ៥

-បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានពិការភាពសម្រាប់រាជធានី ខេត្តទាំង ២៥ ដែលមានអ្នកចូលរួមសរុបចំនួន ៤៦នាក់ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី

-បានរៀបចំសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ និងកម្រងឯកសារបណ្តុះបណ្តាល ដូចជា ១. សៀវភៅណែនាំបណ្តុះបណ្តាលអំពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួល ២. ឧបករណ៍វាយតម្លៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលដោយគ្មានលក្ខណៈបច្ចេកទេស ៣. សៀវភៅណែនាំសម្រាប់គ្រូបង្គោលស្តីពីការបណ្តុះបណ្តាល និងបានរៀបចំវគ្គបណ្តុះបណ្តាលរំលឹកគ្រូបង្គោល ស្តីពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួល

-បានសហការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការកសាងសមត្ថភាពលើការធ្វើបរិយាបន្នពិការភាព នៃគម្រោង ពង្រឹងសមត្ថភាព និងការអប់រំសម្រាប់ជនពិការ ដល់មន្ត្រីពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅភោជនីយដ្ឋាន ទន្លេបាសាក់២

-បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការកសាងផែនការសកម្មភាពស្តារឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ សម្រាប់ជនពិការនៅសណ្ឋាគារភ្នំពេញ

-បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការលើកម្ពស់ការអនុវត្តផែនការស្តារឡើងវិញក្រោយជំងឺកូវីដ-១៩ សម្រាប់ជនពិការ និងឧបករណ៍ស្វែងរកការគាំទ្រនៅសណ្ឋាគារភ្នំពេញ

-បានរៀបចំកិច្ចប្រជុំពិនិត្យលើផែនការស្តារឡើងវិញរយៈពេល ៣ឆ្នាំ ចំពោះជនពិការក្នុងកំឡុងពេលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ នៅសណ្ឋាគារ ប៉ាក់ឌីសៀមរាប

-បានចុះត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តបទដ្ឋានជាតិវិជ្ជាជីវៈព្យាបាលដោយចលនា នៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ស្ពឺ កំពង់ចាម បាត់ដំបង និងខេត្តព្រះសីហនុ

-បានរៀបចំឯកសារណែនាំស្តីពីការអនុវត្តតួនាទី និងភារៈកិច្ចរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ នៅខេត្តត្បូងឃ្មុំ សៀមរាប បាត់ដំបង កំពង់ឆ្នាំង និងខេត្តស្វាយរៀង តាមប្រព័ន្ធ ហ្សូម

-បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលបរិយាបន្នពិការភាពចំនួន ២វគ្គ និងវគ្គជំនាញចំនួន ៥វគ្គ ដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋាន ក.ស.ជ. រួមមាន ភាពជាអ្នកដឹកនាំ តម្រូវការទាំងប្រាំរបស់មនុស្ស ជំនាញត្រួតពិនិត្យនិងវាយតម្លៃ ជំនាញសរសេររបាយការណ៍ និងជំនាញសរសេរគម្រោងស្នើសុំមូលនិធិ

-បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីពិនិត្យ កែសម្រួលរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ

-បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពី ការធ្វើបរិយាបន្ននៅក្នុងដំណើរការរៀបចំ និងការកសាងកម្មវិធីវិនិយោគឃុំសង្កាត់ នៅសណ្ឋាគារ ភ្នំពេញ

-សហការជាមួយអង្គការជនពិការកម្ពុជាបានរៀបចំជម្រាលចំនួន ២៥ជម្រាល នៅតាមឃុំចំនួន ១០ នៃខេត្តចំនួន ៥ គឺ ខេត្តសៀមរាប ៧ជម្រាល កំពង់ស្ពឺ ៧ជម្រាល កំពង់ចាម ៧ជម្រាល បាត់ដំបង ២ជម្រាល និងខេត្តក្រចេះ ២ជម្រាល

-បានចេញលិខិតបញ្ជាក់ពិការភាពជូនជនពិការចំនួន ០៤នាក់ ដើម្បីយកទៅប្រើប្រាស់ផ្សេងៗ

-បានផលិតសៀវភៅមគ្គុទេសក៍គតិយុត្តស្តីពីកាតព្វកិច្ចរបស់និយោជក ក្នុងការជ្រើសរើស និយោជិតពិការចូលបម្រើការងារចំនួន១០ ០០០ក្បាល ដើម្បីចែកជូនដល់ ក្រុមហ៊ុន រោងចក្រ សហគ្រាស ទូទាំងប្រទេស

-មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យ (JCIA) បានបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការក្នុងវគ្គទី២២ ឆ្នាំ២០២១ សរុបចំនួន ៣៥នាក់ ស្រី ០៦នាក់ ក្នុងនោះ ផ្នែកកាត់ដេរសំលៀកបំពាក់ អ៊ុតសក់ និងសម្អាងការ ០៧នាក់ ផ្នែកជួសជុលវិទ្យុទូរទស្សន៍និងបរិក្ខាអគ្គិសនី ១៣នាក់ និងផ្នែកជួសជុល ម៉ូតូ ម៉ាស៊ីនតូចធំ ១៥នាក់

-បានចុះតាមដានត្រួតពិនិត្យដំណើរការកំណត់អត្តសញ្ញាណកម្មជនពិការនៅថ្នាក់ក្រោមជាតិ នៅខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ស្ពឺ សីហនុ និងខេត្តកោះកុង

-បានផលិតវីដេអូចំនួន ៥ស្ពត ណែនាំសម្រាប់មន្ត្រីដែលត្រូវអនុវត្តកំណត់អត្តសញ្ញាណកម្មពិការភាពតាមបែបគំរូសង្គម និងសិទ្ធជាមូលដ្ឋានតាមឃុំ សង្កាត់

-បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្ត ស្តីពីការកំណត់អត្តសញ្ញាណកម្មពិការភាព តាមបែបគំរូសង្គម និងសិទ្ធជាមូលដ្ឋានសម្រាប់ថ្នាក់ខេត្តចំនួន ៧វគ្គ គឺមានរាជធានីភ្នំពេញ ខេត្តតាកែវ កំពង់ស្ពឺ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ កំពង់ឆ្នាំង កែប កំពត កោះកុង កណ្តាល ព្រះសីហនុ ព្រះវិហារ មណ្ឌលគិរី និងខេត្តរតនគិរី ដែលមានអ្នកចូលរួមសរុប ៣៨៧នាក់

-រហូតមកដល់ចុងខែវិច្ឆិកា ឆ្នាំ២០២១ ជនពិការចំនួន ២២០ ៦១៨នាក់ ស្រី ១០៣ ៩៦១នាក់ ត្រូវបានសម្ភាសដើម្បីកំណត់អត្តសញ្ញាណជនពិការតាមតាមបែបគំរូសង្គម និងសិទ្ធជាមូលដ្ឋាន នៅតាមឃុំ សង្កាត់

-បានលុបឈ្មោះជនពិការចេញពីរបបឧបត្ថម្ភជនពិការក្រីក្រនៅសហគមន៍ ៩២៩នាក់ មាន ខេត្តព្រៃវែង កណ្តាល បាត់ដំបង កំពត បន្ទាយមានជ័យ ត្បូងឃ្មុំ តាកែវ កំពង់ធំ ស្វាយរៀង កំពង់ចាម កំពង់ស្ពឺ និងខេត្តឧត្តរមានជ័យ

-បានបោះពុម្ពកាតសម្រាប់ផ្តល់ជូនពិការចំនួន ៥៥ ០០០កាត

-បានចុះត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធជនពិការ របស់រោងចក្រ សហគ្រាស នៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្តកណ្តាលសរុបចំនួន ៤៩រោងចក្រ

-បានចុះបញ្ជិកាជូនរោងចក្រ សហគ្រាស ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សណ្ឋាគារចំនួន ២២២អង្គភាព

-បានចេញប្រកាសទទួលស្គាល់ជនពិការក្រីក្រដើម្បីទទួលបានរបបគោលនយោបាយជនពិការក្រីក្រនៅតាមសហគមន៍ចំនួន ៦២៤នាក់ នៅខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ សរុបជនពិការក្រីក្រចំនួន ១៦ ៨០២នាក់ កំពុងទទួលរបប

-បានជំរុញក្រសួង ស្ថាប័នរដ្ឋ ជ្រើសរើសជនពិការចូលបម្រើការងារតាមអត្រាកំណត់ បច្ចុប្បន្ន ជនពិការ ៣ ៦២១នាក់ កំពុងបម្រើការងារតាមក្រសួង ស្ថាប័នរដ្ឋចំនួន៤៣ និងជនពិការ ៥ ២៣៥នាក់ កំពុងបម្រើការងារនៅក្នុងរោងចក្រ សហគ្រាសវិស័យឯកជន។

**អនុកម្មវិធីទី១.៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់**

-បានរៀបចំកិច្ចប្រជុំអន្តរក្រសួងដើម្បីបំពេញកម្រងសំណួរនៃសេចក្តីព្រាងការស្នងមតិថ្នាក់ជាតិដោយស្ម័គ្រចិត្ត ស្តីពីការអនុវត្តឯកសារផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីដ ស្តីពីមនុស្សចាស់នៅអាស៊ីប៉ាស៊ីហ្វិច

-ពិនិត្យ និងកែសម្រួលអនុក្រឹត្យ លេខ ១៥៨អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សវ័យចាស់

-បានចុះពិនិត្យសមាគមមនុស្សចាស់នៅតាមឃុំ សង្កាត់ និងសមាគមមនុស្សចាស់នៅតាមវត្តអារាម ដើម្បីពង្រឹងសមត្ថភាពសមាគមមនុស្សចាស់ នៅគ្រប់ ២៥ រាជធានី ខេត្ត

-បានប្រមូលធាតុចូលសម្រាប់រៀបចំរបាយការណ៍វឌ្ឍភាពនៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី១ ឆ្នាំ២០១៨-២០២០

-បានសហការជាមួយអង្គការ UNDP រៀបចំសេចក្តីព្រាងផែនការសកកម្មភាពដំណាក់កាលទី២ ឆ្នាំ២០២១-២០២៥ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់២០១៧-២០៣០

-បានរៀបចំសៀវភៅសិក្សា និងកម្មវិធីសិក្សាជំនាញថែទាំមនុស្សវ័យចាស់

-បានឧបត្ថម្ភសាច់ប្រាក់ជូនមនុស្សចាស់អាយុពី ៦០ឆ្នាំឡើង តាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ចំនួន ៣៣៨ ០៧៦នាក់។

**អនុកម្មវិធីទី១.៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន**

-គិតមកដល់បច្ចុប្បន្ន សមាជិកសមាគមអតីតយុទ្ធជនកម្ពុជាសរុបចំនួន ៨០ ៦៩១នាក់

-បានរៀបចំទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា នៅតាមរាជធានី ខេត្ត មួយចំនួន ដូចជា ខេត្តកណ្តាល កំពង់ចាម ស្វាយរៀង សៀមរាប ព្រៃវែង ប៉ៃលិន កំពង់ឆ្នាំង កំពត និងខេត្តកោះកុង

-បានទទួលសំណុំបែបបទស្នើសុំប្រាក់បេឡាមរណសង្គ្រោះពី ស.អ.ក. រាជធានី ខេត្តចំនួន ២ ០៣២សព។ គិតពីឆ្នាំ២០០៨ មកដល់ត្រឹមថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ គណៈអចិន្ត្រៃយ៍ ស.អ.ក. បានទទួលសំណុំបែបបទស្នើសុំប្រាក់ ប.ម.ស. សរុបចំនួន ១៧ ៨៨៩សព និងបានចេញសេចក្តីសម្រេចស្តីពីការប្រគល់ថវិកា ប.ម.ស. ជូនសមាជិក ស.អ.ក. ទាំងស្រុង

-បានឧបត្ថម្ភគ្រឿងឧបភោគ បរិភោគជូនដល់គ្រួសារសពដែលជាសមាជិក ស.អ.ក.ចំនួន ៦២គ្រួសារ។

**កម្មវិធីទី២. ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ**

**អនុកម្មវិធីទី២.១.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល**

-បានរៀបចំបែបបទទទួលស្គាល់មន្ត្រីរាជការឱ្យចូលនិវត្តន៍ និងឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គម ចំនួន ១ ៤៣៤នាក់ និងអ្នកនៅក្នុងបន្ទុក ១ ១១៥នាក់ ព្រមទាំងផ្ទេរការគ្រប់គ្រងទៅតាមរាជធានី ខេត្ត

-បានចេញប្រកាសលុបសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈសរុបចំនួន ១ ៩៦០នាក់ និងបន្តឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកចំនួន ១ ២៤២នាក់

-បានរៀបចំបែបបទបើកប្រាក់របបសន្តិសុខសង្គមរបស់សពមន្ត្រីរាជការស៊ីវិល ៣៧នាក់ និងផ្ទេរកូនសពមន្ត្រីរាជការស៊ីវិល ៤៤នាក់

-កែសម្រួលកាំប្រាក់សោធនជូននិវត្តជន ១០០នាក់ លុបអ្នកនៅក្នុងបន្ទុក ១ ១២៧នាក់

-បានបើកប្រាក់រំលឹកជូននិវត្តជន ១ ៤៩២នាក់

-បានបើកប្រាក់នៅសល់ក្នុងគណនីជូនគ្រួសារសព និវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈ ៦៤៥នាក់

-បានបើកប្រាក់របបសន្តិសុខសង្គមជូនគ្រួសារសពនិវត្តជន និងគ្រួសារសពជនបាត់បង់សម្បទាវិជ្ជាជីវៈ ១ ៨៣២នាក់

-បានបើកប្រាក់របបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកសពនិវត្តជន សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងបន្ទុករបស់សពមន្ត្រីរាជការស៊ីវិលចំនួន ១១ ៧៥៣នាក់

-បានផ្ទេរសិទ្ធិជូនសិទ្ធិវន្តដែលមានជំងឺស្នើសុំផ្ទេរសិទ្ធិចំនួន ១០៣នាក់

តារាងទី៥៖ ទិន្នន័យធ្វើបច្ចុប្បន្នភាពសិទ្ធិវន្តរបស់ ប.ជ.ស. ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២១

| លរ | សិទ្ធិវន្ត | ចំនួន | អ្នកនៅក្នុងបន្ទុក | | | | |
|---|---|---|---|---|---|---|---|
| | | | ប្រពន្ធ | កូន | ប្រពន្ធសព | កូនសព | កូនសពមន្ត្រីរាជការស៊ីវិល |
| ១ | និវត្តជន | ៩៧២ | ៣៣៨ | ១៤៥ | ៧ | ១៥ | ០ |
| ២ | ជនបាត់បង់សម្បទាវិជ្ជាជីវៈ | ១ | ០ | ០ | ០ | ០ | |
| ៣ | អ្នកនៅក្នុងបន្ទុក | ៥០៥ | ៣៣៨ | ១៤៥ | ៧ | ១៥ | ០ |
| សរុបរួម | | ១ ៤៧៨ | | | | | |

(ប្រភព ប.ជ.ស. )

តារាងទី៦៖ ទិន្នន័យសរុបរបស់សិទ្ធិវន្តដែលធ្វើបច្ចុប្បន្នភាពគិតត្រឹមខែធ្នូ ឆ្នាំ២០២១

| លរ | សិទ្ធិវន្ត | ចំនួន | អ្នកនៅក្នុងបន្ទុក | | | | |
|---|---|---|---|---|---|---|---|
| | | | ប្រពន្ធ | កូន | ប្រពន្ធសព | កូនសព | កូនសពមន្ត្រីរាជការស៊ីវិល |
| ១ | និវត្តជន | ៥៦ ២៤១ | ៣០ ៦០២ | ៣ ៣៩១ | ៨ ៦៦៣ | ២៩២ | ១២៨ |
| ២ | ជនបាត់បង់សម្បទាវិជ្ជាជីវៈ | ១ ៨៤៧ | ៧៩១ | ០២ | ៩៦៦ | ៦ | |
| ៣ | អ្នកនៅក្នុងបន្ទុក | ៤៤ ៨៤១ | ៣១ ៣៩៣ | ៣ ៣៩៣ | ៩ ៦២៩ | ២៩៨ | ១២៨ |
| សរុបរួម | | ១០២ ៩២៩ | | | | | |

(ប្រភព ប.ជ.ស. )

តារាងទី៧៖ ទិន្នន័យសិទ្ធិវន្តនៃ ប.ជ.ស. ដែលកំពុងបើករបបតាមប្រព័ន្ធធនាគារ គិតត្រឹមខែធ្នូ ឆ្នាំ២០២១

| លរ | សិទ្ធិវន្ត | ចំនួន | អ្នកនៅក្នុងបន្ទុក | |
|---|---|---|---|---|
| | | | ប្រពន្ធ | កូន |
| ១ | និវត្តជន | ៥៤ ៧៩៥ | ២៩ ៤៨៦ | ៤ ១០០ |
| ២ | ជនបាត់បង់សម្បទាវិជ្ជាជីវៈ | ១ ៦៧៧ | ៧២៥ | ៦ |
| ៣ | អ្នកនៅក្នុងបន្ទុក | ៣៤ ៣១៧ | ៣០ ២១១ | ៤១០៦ |
| សរុបរួម | | ៩០ ៧៨៩ | | |

(ប្រភព ប.ជ.ស. )

**អនុកម្មវិធីទី២.២. ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ**

-ទទួលអតីតយុទ្ធជនដែលផ្ទេរពីក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃសរុបចំនួន ៧ ៦២៨នាក់

-បញ្ចូលបន្ទុកអតីតយុទ្ធជន ១៧៨នាក់ និងលុបបន្ទុកអតីតយុទ្ធជន ២ ៥៨៩នាក់

-ផ្ទេរអតីតយុទ្ធជនតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត ៤៦០នាក់ និងទទួលស្គាល់របបឧបត្ថម្ភឡើងវិញ ១៦នាក់

-ផ្តល់ប្រាក់បូជាសព មួយលើកដំបូង និងប្រាក់ធានារ៉ាប់រងសង្គម ១ ៥៨៥នាក់

-ផ្តល់ប្រាក់វិលទៅមូលដ្ឋានមួយលើកដំបូងជូនជនពិការ ១ ២៧១នាក់

តារាងទី៨៖ កំណត់ប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារក្នុងឆ្នាំ២០២១

| លរ | មុខសញ្ញា | ចំនួន | បន្ទុកដែលត្រូវទទួលរបប | | | | | | | ទឹកប្រាក់សរុប (៛) |
|---|---|---|---|---|---|---|---|---|---|---|
| | | | ឪពុក | ម្តាយ | អា ព្យា | ប្រពន្ធ | កូន | អ្នកបម្រើ | សរុប | |
| ១ | ជនពលី | ២១៤ | ៧៥ | ១២៨ | ២ | ១៦២ | ២៥៨ | | ៦២៥ | ៦ ៦៥០ ០០០ |
| ២ | ជនមរណៈ | ២១៩ | ៥៤ | ១០៨ | ៣ | ១៩៤ | ២៣៨ | | ៥៩៧ | ៦ ៦១០ ០០០ |
| ៣ | ជនពិការ | ១ ៩០២ | | | | ១ ៤៩៧ | ១ ២៧៩ | ២២២ | ២ ៩៩៨ | ២ ៦៥៥ ១៤០ ៩០០ |
| ៤ | និវត្តជន | ៣ ៨៧០ | | | | ៣ ២០២ | ៣ ២០៦ | | ៦ ៤០៨ | ៤ ៥៨០ ១៨២ ៦៩១ |
| ៥ | ជនបាត់បង់ | ១ | | | | ១ | | | ១ | ១ ០៨៣ ៣៧៥ |
| សរុប | | ៦ ២០៦ | ១២៩ | ២៣៦ | ៥ | ៥ ០៥៦ | ៤ ៩៨១ | ២២២ | ១០ ៦២៩ | ៧ ២៤៩ ៦៦៦ ៩៦៦ |

(ប្រភព ប.ជ.អ. )

តារាងទី៩៖ លុបឈ្មោះអតីតយុទ្ធជនដែលទទួលមរណភាព និងទទួលស្គាល់ជាជនពលី និងមរណៈវិញ

| លរ | មុខសញ្ញា | ចំនួន | បន្ទុកដែលទទួលប្រាក់ឧបត្ថម្ភក្នុងរយៈពេល ៩ខែ ឆ្នាំ ២០២១ | | | | | | | ទឹកប្រាក់សរុប (៛) |
|---|---|---|---|---|---|---|---|---|---|---|
| | | | ឪពុក | ម្តាយ | អា ព្យា | ប្រពន្ធ | កូន | អ្នកបម្រើ | សរុប | |
| ១ | ជនពិការ | ៤៥១ | ៣៥ | ៥០ | | ៤២៥ | ១៧៥ | | ៦៨៥ | ៩៦ ១០៤ ៣៥៤ |
| ២ | និវត្តជន | ៨០១ | ៩ | ១៣ | | ៧៥៤ | ១៩៣ | | ៩៦៩ | ២៤២ ៩៨៧ ៥១៨ |
| ៣ | ជនបាត់បង់ | ៩ | | ១ | | ៨ | ៤ | | ១៣ | ១៦៨ ០០០៛ |
| សរុប | | ១ ២៦១ | ៤៤ | ៦៤ | | ១ ១៨៧ | ៣៧២ | | ១ ៦៦៧ | ៣៣៩ ២៥៩ ៨៧២ |

(ប្រភព ប.ជ.អ. )

តារាងទី១០៖ លុបឈ្មោះអតីតយុទ្ធជន និងគ្រួសារចេញពីបញ្ជីបើកប្រាក់ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២១

| ល.រ | មុខសញ្ញា | ចំនួន | បន្ទុកដែលត្រូវកាត់ចេញ | | | | | | | ទឹកប្រាក់សរុប (៛) |
|---|---|---|---|---|---|---|---|---|---|---|
| | | | ឪពុក | ម្តាយ | អា ព្យា | ប្រពន្ធ | កូន | អ្នកបម្រើ | សរុប | |
| ១ | ជនពលី | ៣៥៦ | ៧៣ | ២០៩ | ១ | ១៤៩ | ៣៨ | | ៤៧០ | ៤ ៨៧៩ ០០០ |
| ២ | ជនមរណៈ | ៦៦ | ៧ | ១៤ | ១ | ៤១ | ២៩ | | ៩២ | ១ ០៨១ ០០០ |
| ៣ | ជនពិការ | ១១៣ | | | | | | | | ៨១ ៨៨៦ ២២០ |
| ៤ | និវត្តជន | ៩១ | | | | ១ | | | ១ | ៦៧ ៦០៥ ៤៦៨ |
| ៥ | ជនបាត់បង់ | ១ | | | | | | | | |
| សរុប | | ៦២៧ | ៨០ | ២២៣ | ២ | ១៩១ | ៦៧ | | ៥៦៣ | ១៥៥ ៤៥១ ៦៨៨ |

(ប្រភព ប.ជ.អ. )

តារាងទី១១៖ អតីតយុទ្ធជន និងគ្រួសារដែលកំពុងទទួលប្រាក់របបសន្តិសុខសង្គមក្នុងខែធ្នូ ឆ្នាំ២០២១

| ល.រ | មុខសញ្ញា | ចំនួន | បន្ទុកដែលត្រូវទទួលរបប | | | | | | | ទឹកប្រាក់សរុប (៛) |
|---|---|---|---|---|---|---|---|---|---|---|
| | | | ឪពុក | ម្តាយ | អា ព្យា | ប្រពន្ធ | កូន | អ្នកបម្រើ | សរុប | |
| ១ | ជនពលី | ២៦ ៨២៩ | ៥ ៦០២ | ១០ ៩០២ | ១៧៦ | ២០ ៤១០ | ៨ ១៨៨ | | ៤៥ ២៧៨ | ៥២១ ៥២៦ ០០០ |
| ២ | ជនមរណៈ | ៩ ៤២៧ | ១ ១៩២ | ២ ២៣៦ | ៣២ | ៨ ៧០១ | ៤ ៨៥៧ | | ១៧ ០១៨ | ២០៦ ៩២៤ ០០០ |
| ៣ | ជនពិការ | ២៨ ៦៨៧ | | | | ២៤ ៣៤១ | ១៣ ៦៧៦ | ១ ៦៣១ | ៣៩ ៦៤៨ | ២២ ២៦១ ១២៤ ៤៤០ |
| ៤ | និវត្តជន | ៣៦ ២១១ | | | | ៣០ ៥២១ | ១៥ ៩៦២ | | ៤៦ ៤៨៣ | ៣១ ២៨២ ៤៣៩ ១១៩ |
| ៥ | ជនបាត់បង់ | ១ ៤៧៤ | | | | ១ ១០០ | ៤៩១ | ៦៨ | ១ ៦៥៩ | ៩៤៨ ៨៥៧ ៦៩៨ |
| សរុប | | ១០២ ៦២៨ | ៦ ៧៩៤ | ១៣ ១៣៨ | ២០៨ | ៨៥ ០៧៣ | ៤៣ ១៧៤ | ១ ៦៩៩ | ១៥០ ០៨៦ | ៥៥ ២២០ ៨៧១ ២៥៧ |

(ប្រភព ប.ជ.អ. )

## អនុកម្មវិធីទី២.៣.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ

-បានទទួលប្រាក់ភាគទានពីក្រសួង ស្ថាប័ន និងនីតិបុគ្គលដែលមិនបានជ្រើសរើសជនពិការចូលបម្រើការងារចំនួន ១៣៥ ០៦៩ ០៦៩៛

-គ្លីនិកព្យាបាលដោយចលនាបានទទួលអតិថិជនមកព្យាបាល ដោយទទួលបានថវិកាសរុបចំនួន ២៧០ ០០០៛

-បានដាក់ហិបមូលនិធិជនពិការនៅតាមរាជធានី/ខេត្ត និងប្រមូលបានថវិកាសរុបចំនួន ៦៩ ៨២២ ៧០០៛

-មូលនិធិជនពិការតាមរយៈមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងអង្គការដៃគូបានផ្តល់សេវាស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទជូនជនពិការ ៣៣ ៣១៨នាក់ ក្នុងនោះសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ១២ ៦១៧នាក់ និងស្តារវេជ្ជសាស្ត្រ ២០ ៧០១នាក់

-បានសាងសង់ផ្ទះជូនជនពិការក្រីក្រចំនួន ៨ខ្នង នៅខេត្តត្បូងឃ្មុំ២ខ្នង រាជធានីភ្នំពេញ១ខ្នង កំពង់ធំ១ខ្នង តាកែវ១ខ្នង កំពង់ចាម១ខ្នង កំពង់ឆ្នាំង១ខ្នង និងព្រៃវែង១ខ្នង

-បានផ្តល់អំណោយសប្បុរសធម៌ជារបស់ ម.ជ.ព. ជូនជនពិការក្រីក្រចំនួន ៥៦២នាក់ នៅខេត្តកណ្តាល កំពង់ស្ពឺ កែប ព្រៃវែង បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពត ត្បូងឃ្មុំ ស្វាយរៀង ក្រចេះ កំពង់ចាម កំពង់ឆ្នាំង និងខេត្តឧត្តរមានជ័យ

-បានផ្តល់ប្រាក់ឧបត្ថម្ភរបបគោលនយោបាយសម្រាប់ពិនិត្យ និងថែទាំសុខភាពជូនជនពិការក្រីក្រនៅតាមសហគមន៍ចំនួន ៩ ២៥២នាក់ នៅរាជធានីភ្នំពេញ ខេត្តត្បូងឃ្មុំ កំពង់ស្ពឺ និងខេត្តព្រៃវែង ដោយម្នាក់ៗទទួលបានថវិកា ៣០ ០០០៛។

### ២.៣.១.ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា

-ដោយមានការសហការ ជួយឧបត្ថម្ភរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមានកិច្ចសហការជាមួយក្រសួង ស.អ.យ. មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងរោងជាងសរុបចំនួន ១៥កន្លែង បានផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាគ្រប់ប្រភេទជូនជនពិការសរុបចំនួន ១២ ៦១៧នាក់ ស្រី ៣ ២៤១នាក់ និងជនពិការដោយសារមីន ៤ ៥៤៤នាក់។ ទន្ទឹមនេះ ជនពិការដែលមកទទួលសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មដោយឥតគិតថ្លៃ ព្រមទាំងបានទទួលការឧបត្ថម្ភជាប្រាក់ អាហារ និងថ្លៃធ្វើដំណើរទៅមកផងដែរ

-បានផ្តល់អវយវៈសិប្បនិម្មិត រណប និងឧបករណ៍ជំនួយការរាងកាយសរុបចំនួន ៥ ៤៥៦គ្រឿង/កាយ

-បានជួសជុលឧបករណ៍សិប្បនិម្មិត រណប និងឧបករណ៍ជំនួយរាងកាយសរុបចំនួន ៧ ២២០គ្រឿង/កាយ

-បានព្យាបាលដោយចលនាចំនួន ២ ៩៨៤នាក់ ស្មើនឹងចំនួនព្យាបាល ២៩ ០៤៧ដង

-ផ្តល់ការស្នាក់នៅជូនជនពិការអំឡុងពេលទទួលសេវាបាន ៣ ៤៣៦នាក់ និងអ្នកកំដរ ៥២៤នាក់។

**២.៣.២. ការផ្តល់សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ**

បានពិនិត្យ និងព្យាបាល វះកាត់ភ្នែក ដាក់កែវភ្នែកសិប្បនិម្មិត ដាក់កញ្ចក់ក្នុងកែវភ្នែក ផ្តល់វ៉ែនតា វះកាត់ដៃជើងនិងមុខមាត់ ព្យាបាលជំងឺហង់សិន និងព្យាបាលអ្នកជំងឺរបួសខួរឆ្អឹងខ្នងបានចំនួនសរុប ២០ ៧០១នាក់ ស្រី ១១ ១០៦នាក់។

**២.៣.៣.ការផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍**

-ជនពិការបានទទួលសេវាជួសជុលចល័តនូវឧបករណ៍សិប្បនិម្មិតនិងឈោប ២ ៤៤៧នាក់

-បានផ្តល់ រទេះរុញនិងរទេះកង់បី ១៧៩គ្រឿង ឈើច្រត់ ៣២៤រាយ និងស្បែកជើងខ្ពស់ទាប ៨៣គូ

-បានបញ្ជូនជនពិការទៅកាន់អង្គការ ឬអ្នកផ្តល់សេវាផ្សេងៗ ១៣៤នាក់

-បានបញ្ជូនកុមារពិការទៅសាលារដ្ឋ ១៦៩នាក់

-បានស្រាវជ្រាវឃើញជនពិការថ្មីដែលត្រូវបញ្ជូនទៅទទួលសេវានៅមណ្ឌល ១៤នាក់

-សម្របសម្រួលជួយរកការងារឱ្យធ្វើ ៣០នាក់

-បានផ្តល់កង់ជូនជនពិការចំនួន ២១នាក់

-ចំនួនអាជីវកម្មខ្នាតតូចដែលបានបង្កើត ៤៥នាក់

-បានចុះសួរសុខទុក្ខអ្នកជំងឺនៅក្នុងសហគមន៍ ៣២៧នាក់។

**កម្មវិធីទី៣. ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូ**

**អនុកម្មវិធីទី៣.១. ការពង្រឹងសមត្ថភាពស្ថាប័ន និងភាពជាដៃគូ**

**៣.១.១. ការងាររដ្ឋបាល និងបុគ្គលិក**

-បានរក្សាទុក និងតម្កល់លិខិតបទដ្ឋានគតិយុត្ត មានសណ្តាប់ធ្នាប់ របៀបរៀបរយ ត្រឹមត្រូវ និងលាក់ការណ៍សម្ងាត់

-ក្របខ័ណ្ឌមន្ត្រីរាជការសរុបចំនួន ១ ៨១០នាក់ ស្រី ៧០៩នាក់ (ថ្នាក់ជាតិ ៩៦៤នាក់ និងក្រោមជាតិ ៨៤៦នាក់) និងមន្ត្រីកិច្ចសន្យា ៥៥៦នាក់

-តែងតាំង និងប្រគល់ភារកិច្ច ១៧នាក់ និងផ្តល់នីត្យានុកូលភាពជូនមន្ត្រីចំនួន ៩

-ផ្ទេរផ្ទៃក្នុងក្រសួង ២នាក់

-លុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌ ១៤នាក់

-ការផ្ទេរក្របខ័ណ្ឌចូលក្រសួង ១៨នាក់ ចូលនិវត្តន៍ ៥៣នាក់ និងសម្រួលភារកិច្ច ២៧នាក់

-ការរៀបប្រាក់បៀវត្សមន្ត្រីរាជការដែលតែងតាំង ៩៦នាក់

-ការរៀបប្រាក់បៀវត្សដែលដំឡើងឋានន្តរស័ក្តិ និងថ្នាក់ ៤៧៥នាក់

-ការផ្តាច់ប្រាក់មន្ត្រីឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ០៧នាក់

-ការផ្តាច់ប្រាក់បៀវត្សមន្ត្រីចូលនិវត្តន៍ ០៨នាក់

-លំហែមាតុភាព ២នាក់

-ផ្តល់ប្រាក់ឧបត្ថម្ភអ្នកនៅក្នុងបន្ទុកមន្ត្រីរាជការ ៧៤នាក់ និងផ្តាច់ប្រាក់ឧបត្ថម្ភអ្នកនៅក្នុងបន្ទុក ១៩នាក់

-បានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ក្នុងប្រទេស ៨៥នាក់ និងក្រៅប្រទេស ០១នាក់។

**៣.១.២. ការងារផែនការ ស្ថិតិ និងសរុប**

-បានរៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាសទី១ ឆមាស ៩ខែ ឆ្នាំ២០២១ របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២១ និងរបាយការណ៍បូកសរុបលទ្ធផលការងារ ៥ឆ្នាំ ២០១៧-២០២១ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

-បានរៀបចំផែនការសកម្មភាពដំណាក់កាលទី៣ ឆ្នាំ២០២២-២០២៤ នៃការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០

-បានរៀបចំផែនការសកម្មភាព ៣ឆ្នាំរំកិល ២០២១-២០២៣

-បានរៀបចំកម្មវិធីវិនិយោគសាធារណៈ ២០២០-២០២៤ របស់ក្រសួង មាន ៧គម្រោង ក្នុងនោះ គម្រោងកំពុងអនុវត្ត ០១គម្រោង

-បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត នៅខេត្តត្បូងឃ្មុំ មានអ្នកចូលរួមចំនួន ៣៤០នាក់។

**៣.១.៣.ការងារគ្រប់គ្រងថវិកា និងសម្ភារ**

-បានបើកប្រាក់បៀវត្សរ៍ប្រចាំខែ ជូនមន្ត្រីរាជការ បានទាន់ពេលវេលា

-បានផ្គត់ផ្គង់សម្ភារ បរិក្ខារ សង្ហារឹម ការជួសជុល និងប្រេងឥន្ធនៈ ជូនថ្នាក់ដឹកនាំ និងអង្គភាពក្រោមឱវាទ។

តារាងទី១២៖ ស្ថានភាពថវិកាថ្នាក់ជាតិឆ្នាំ២០២១

| ជំពូក | ច្បាប់ថវិកា ឆ្នាំ២០២១ | ឥណទានថ្មី | បានអនុវត្ត | ឥណទាននៅសល់ | ការចំណាយ (%) |
|---|---|---|---|---|---|
| **សរុប** | **១ ២៣៥ ៧៦៦ ០០០ ០០០** | **១ ៣០៣ ៤៨១ ៨២០ ០០០** | **១ ២៧០ ០៧៤ ៥៧៧ ៩០៤** | **៣៣ ៤០៧ ២៤២ ០៩៦** | **៩៧,៤៤%** |
| ៦០ | ៤ ៣១៧ ០០០ ០០០ | ៤ ២៣៨ ០៧០ ០០០ | ៣ ៧៩៩ ០៥៤ ២១៨ | ៤៣៩ ០១៥ ៧៨២ | ៨៩,៦៤% |
| ៦១ | ៧ ០២៨ ០០០ ០០០ | ៦ ៦៥០ ៧៦០ ០០០ | ៥ ៥៧៨ ៧១៨ ៨៨៣ | ១ ០៧២ ០៤១ ១១៧ | ៨៣,៨៨% |
| ៦៤ | ២០ ៩៤៦ ០០០ ០០០ | ២១ ៥៧៧ ០០០ ០០០ | ២១ ២០៤ ១៧០ ៨៣៣ | ៣៧២ ៨២៩ ១៦៧ | ៩៨,២៧% |
| ៦២ | ១ ១៨៣ ៩៦៨ ៩០០ ០០០ | ១ ២៥១ ៤៨២ ៨៤០ ០០០ | ១ ២២១ ១៤១ ៥៣១ ៤៧០ | ៣០ ៣៤១ ៣០៨ ៥៣០ | ៩៧,៥៨% |
| ៦៥ | ១៩ ៤៨១ ១០០ ០០០ | ១៩ ៥០៨ ១៥០ ០០០ | ១៨ ៣២៩ ១០៧ ៥០០ | ១ ១៧៩ ០៤២ ៥០០ | ៩៣,៩៦ |
| ៦៣ | ២៥ ០០០ ០០០ | ២៥ ០០០ ០០០ | ២១ ៩៩៥ ០០០ | ៣ ០០៥ ០០០ | ៨៧,៩៨ |

តារាងទី១៣៖ ស្ថានភាពថវិកាថ្នាក់មន្ទីររាជធានី ខេត្ត ឆ្នាំ២០២១

| ជំពូក | ច្បាប់ថវិកា ឆ្នាំ២០២១ | ឥណទានថ្មី | បានអនុវត្ត | ឥណទាននៅសល់ | ការចំណាយ % |
|---|---|---|---|---|---|
| សរុប | ៥១ ៩២៩ ០០០ ០០០ | ៥១ ៩២៩ ០០០ ០០០ | ៤៩ ៦០៥ ០៥៦ ៨៣៧ | ២ ៦៨៣ ៥៦៣ ១៦៣ | ៩៥,៥២% |
| ៦០ | ៣ ៤០៨ ០០០ ០០០ | ៣ ៤០៨ ០០០ ០០០ | ៣ ១៧៩ ៣៥១ ៦៥៩ | ២២៨ ៦៤៨ ៣៤១ | ៩៣,២៩% |
| ៦១ | ១២ ៤៩១ ០០០ ០០០ | ១២ ៤៩១ ០០០ ០០០ | ១១ ៨៥២ ១២៤ ៥៤២ | ៦៣៨ ៨៧៥ ៤៥៨ | ៩៤.៨៩% |
| ៦៤ | ១៧ ៥២៨ ០០០ ០០០ | ១៧ ៥២៨ ០០០ ០០០ | ១៥ ៨៦១ ៤៧១ ៥២៦ | ១ ៦៦៦ ៥២៨ ៤៧៤ | ៩០,៤៩% |
| ៦២ | ១៨ ៤៨១ ០០០ ០០០ | ១៨ ៤៨១ ០០០ ០០០ | ១៨ ៧០២ ៧៥៩ ១១០ | ១៣៧ ៨៦០ ៨៩០ | ៩៩,២៧% |
| ៦៣ | ២១ ០០០ ០០០ | ២១ ០០០ ០០០ | ៩ ៣៥០ ០០០ | ១១ ៦៥០ ០០០ | ៤៤,៥២ |

**៣.១.៤ ការងារសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន**

-បានចុះត្រួតពិនិត្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១៥ និងបានចុះកិច្ចព្រមព្រៀងជាមួយអង្គការចំនួន ២៦

-បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអង្គការដែលចុះកិច្ចព្រមព្រៀងនៅមានសុពលភាពជាមួយក្រសួងចំនួន ១៥២ ដែលមានថវិកាសរុបចំនួន ៣២៤ ៤៧៨ ២២៥,៥០ដុល្លារអាម៉េរិក

-បានសម្របសម្រួលផ្តល់លិខិតគាំទ្រសម្រាប់អង្គការស្នើសុំបន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជូនអង្គការ ១៨ករណី

-បានសម្របសម្រួលលិខិតគាំទ្រនាំចូលរថយន្តរបស់អង្គការមិនមែនរដ្ឋាភិបាលដោយពន្ធ និងអាករជាបន្ទុករបស់រដ្ឋចំនួន ១០ករណី

-បានសម្របសម្រួលចេញលិខិតគាំទ្រស្នើសុំស្លាកលេខប្រភេទអង្គការចំនួន ៥ករណី

-បានសម្របសម្រួលចេញលិខិតគាំទ្រពន្យាទិដ្ឋាការជូនបុគ្គលិកសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១០

-កំណត់ហេតុចំនួន ០២ គឺកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម លើក១៩ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២១ និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា-ថៃ លើកទី១១ ថ្ងៃទី១៦-១៨ ខែធ្នូ ឆ្នាំ២០២១ ត្រូវបានចុះហត្ថលេខា ដោយភាគីទាំងពីរ

-បានរៀបចំឯកសារ និងស្នើសុំលិខិតឆ្លងដែនប្រភេទការទូត ជូនថ្នាក់ដឹកនាំក្រសួង ស.អ.យ. ចំនួន ០៥រូប

-បានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២០ ក្នុងការអនុវត្តក្របខណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍នៃប្រព័ន្ធអង្គការសហប្រជាជាតិឆ្នាំ២០១៩-២០២៣ ចំនួន ០១ ឯកសារ

-បានទទួលបដិសណ្ឋារកិច្ច និងបកប្រែជូនឯកឧត្តមរដ្ឋមន្ត្រី ទទួលជួបភ្ញៀវបរទេសសម្តែងការគួរសម និងពិភាក្សាការងារចំនួន ០២ដង

-ឯកសារចំនួន ៥ បានត្រូវអនុម័ត និងកត់សម្គាល់ ដោយកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៨ និងលើកទី៣៩ ឆ្នាំ២០២១ រួមមាន ១) សេចក្តីប្រកាសបាណ្ឌារសេរីបេហ្គាវ៉ាន់ ស្តីពីសារៈសំខាន់នៃគ្រួសារសម្រាប់ការអភិវឌ្ឍសហគមន៍ និងកសាងសង្គមជាតិ ២) សេចក្តីប្រកាសស្តីពីការលុបបំបាត់ការសម្លុតគំរាមកំហែងនៅតំបន់អាស៊ាន ៣) ផែនទីបង្ហាញផ្លូវអាស៊ានសម្រាប់អនុវត្តសេចក្តីប្រកាសហាណូយ ស្តីពីការពង្រឹងការងារសង្គម សម្រាប់ភាពស្អិតរមួត និងឆ្លើយតបសហគមន៍អាស៊ាន ៤) ផែនការសកម្មភាពថ្នាក់តំបន់ សម្រាប់កិច្ចគាំពារកុមារពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ច និងរំលោភបំពានតាមប្រព័ន្ធអនឡាញក្នុងតំបន់អាស៊ាន និង ៥) ផែនការសកម្មភាពថ្នាក់តំបន់ ស្តីពីការអនុវត្តសេចក្តីប្រកាសអាស៊ាន ស្តីពីសិទ្ធិកុមារក្នុងបរិបទទេសន្តប្រវេសន៍។

**៣.១.៥. សវនកម្មផ្ទៃក្នុង**

-ក្នុងឆ្នាំ២០២១នេះ ក្រសួងបានចុះធ្វើសវនកម្មនៅខេត្តបន្ទាយមានជ័យ បាត់ដំបង ស្ទឹងត្រែង ក្រចេះ កំពង់ធំ កំពង់ឆ្នាំង កំពង់ស្ពឺ តាកែវ និងរាជធានីភ្នំពេញ ដើម្បីកែលម្អការគ្រប់គ្រងចំណាយថវិការដ្ឋ និងទ្រព្យសម្បត្តិរដ្ឋ នៅតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត សំដៅលើកកម្ពស់គណនេយ្យភាព តម្លាភាព ប្រសិទ្ធភាពនៃការផ្តល់សេវាសង្គមកិច្ចគ្រប់ប្រភេទ។

**៣.១.៦. ការងារអធិការកិច្ច**

-បានចុះធ្វើអធិការកិច្ចនៅតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត ចំនួន ១២ ក្នុងនោះ រួមមាន រាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ស្វាយរៀង ព្រៃវែង កំពង់ស្ពឺ ព្រះសីហនុ កំពត កែប តាកែវ និងខេត្តកណ្តាល សំដៅពង្រឹងការអនុវត្តបទបញ្ញាផ្ទៃក្នុង របៀបរបបការងារ វិន័យ ការគ្រប់គ្រងវត្តមានមន្ត្រី និងការរៀបចំទុកដាក់រក្សាទុកលិខិតស្នាមរដ្ឋបាល ព្រមទាំងបានដោះស្រាយភាពមិនប្រក្រតី និងបណ្តឹងចំនួន ២ករណី ដែល១ករណីបានសះជា និង១ករណីទៀតកំពុងបន្តដោះស្រាយ។

**អនុកម្មវិធីទី៣.២.ការអភិវឌ្ឍធនធានមនុស្ស**

- វិទ្យាស្ថានជាតិសង្គមកិច្ច បាននិងកំពុងបណ្តុះបណ្តាលនិស្សិតកម្រិតឧត្តមសិក្សាលើជំនាញសង្គមកិច្ច ជំនាញសង្គមវិទ្យា ជំនាញកិច្ចគាំពារសង្គម ជំនាញវិស្វកម្មឧបករណ៍សិប្បនិម្មិតនិងរណប ជំនាញគ្រប់គ្រងសាធារណៈ ជំនាញរដ្ឋបាលសាធារណៈ ជំនាញគោលនយោបាយសង្គម ជំនាញគោលនយោបាយសាធារណៈ និងជំនាញអក្សរសាស្ត្រអង់គ្លេស សរុបចំនួន ៤៦៣នាក់ (ស្រី២៧៥នាក់)។ ដោយឡែកនិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រសរុបចំនួន ៧០នាក់(ស្រី៣៥នាក់) និងសិក្ខាកាមដែលបានបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រសរុបចំនួន ៥៨នាក់(ស្រី ២៧នាក់)។

- ប្រកាសផ្សព្វផ្សាយ និងដាក់ប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមផ្តោតលើកិច្ចការពារកុមារ ២០២១-២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ នៅទីស្តីការក្រសួង ស.អ.យ. និងសមាសភាពអញ្ជើញចូលរួមសរុបចំនួន ៣៥០នាក់។

II-<u>**ទិសដៅអនុវត្តបន្ត**</u>

**កម្មវិធីទី១. ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម**

**អនុកម្មវិធីទី១.១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ**

- បន្តរៀបចំកម្មវិធីជំនួយសង្គមជាកញ្ចប់គ្រួសារ តាមរយៈ ការធ្វើសមាហរណកម្មកម្មវិធីជំនួយសង្គមបញ្ចូលគ្នា រួមមាន កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម ២ឆ្នាំ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនពិការ កម្មវិធី

ឧបត្ថម្ភមនុស្សវ័យចាស់ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនសិស្សក្រីក្រនៅតាមភូមិសិក្សា និងបន្តរៀបចំប្រព័ន្ធគ្រប់គ្រង និងការឆ្លើយតបគ្រោះអាសន្នក្នុងការផ្តល់ជំនួយសង្គម

- សិក្សា និងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យជនចំណាកស្រុក សំដៅផ្តល់សេវាឆ្លើយតបបន្ទាន់សម្រាប់ជនចំណាកស្រុក និងបង្កាទប់ស្កាត់ជនអនាថា
- ដោះស្រាយបញ្ហាជនអនាថាតាមរយៈការផ្តល់សេវាអប់រំផ្លូវចិត្ត ពិគ្រោះយោបល់ ការថែទាំសុខភាព ស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បង្កឱកាសស្តារជីវភាពនិងធ្វើសមាហរណកម្មទៅក្នុងសង្គមដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស។ ទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ តាមរយៈ ការផ្សព្វផ្សាយអប់រំ ការបញ្ជ្រាបការយល់ដឹងស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងមជ្ឈមណ្ឌលសំចតសង្គមកិច្ច និងការទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅក្នុងមជ្ឈមណ្ឌលព្យាបាលនិងថែទាំជនវិបល្លាសស្មារតី
- ផ្តល់សេវាថែទាំគាំទ្រ និងសង្គ្រោះជនរងគ្រោះ និងជនរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ
- អនុវត្តកម្មវិធីអភិវឌ្ឍគ្រួសារល្អ ការចិញ្ចឹមកូនបែបវិជ្ជមាន ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដោយប្រមូលផ្តុំលើ ការសិក្សា និងរៀបចំគោលនយោបាយជាតិ ស្តីពីការគាំពារគ្រួសារ ការរៀបចំទិវាអន្តរជាតិ ស្តីពីគ្រួសារ ១៥ឧសភា ការបញ្ជ្រាបការងារយេនឌ័រទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ
- សិក្សាដាក់ឱ្យដំណើរការការចុះបញ្ជីកម្លាំងសេវាសង្គម ដើម្បីពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាដល់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទ ដោយប្រមូលផ្តុំលើការរៀបចំអនុក្រឹត្យស្តីពីក្រមសីលធម៌សម្រាប់កម្លាំសេវាសង្គម ផែនការយុទ្ធសាស្ត្រជាតិស្តីពីកម្លាំងសេវាសង្គមនៅកម្ពុជា និងលិខិតគតិយុត្តនានា
- ផ្តល់កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ ដោយប្រមូលផ្តុំលើ ការផ្តល់សេវាការពារផ្លូវច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភផ្លូវភេទ ការប្រឹក្សាយោបល់ ការបញ្ជូនទៅស្តារនីតិសម្បទា និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងរំលោភផ្លូវភេទ មុនធ្វើសមាហរណកម្ម និងការតាមដានបន្ត
- ទទួល និងធ្វើមាតុភូមិនិវត្តជនរងគ្រោះដោយអំពើជួញដូរមនុស្សដោយគ្មានការមាក់ងាយ និងរើសអើង ដោយប្រមូលផ្តុំលើ ការបង្កើតនិងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្ស (Database Management System for Victims of Human Trafficking) ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការជួយគាំពារ និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងមជ្ឈមណ្ឌលសំចតប៉ោយប៉ែតសម្រាប់ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សឆ្លងដែន។

**អនុកម្មវិធីទី១.២.ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា**

- បន្តពង្រឹងប្រព័ន្ធ និងគុណភាពសេវាកិច្ចការពារកុមារ ដោយប្រមូលផ្តុំលើការបង្កើតនិងដាក់ឱ្យដំណើរការប្រព័ន្ធទិន្នន័យថ្នាក់ជាតិដើម្បីគ្រប់គ្រងទិន្នន័យកុមាររងគ្រោះនិងងាយរងគ្រោះ
- ការលើកកម្ពស់សមត្ថភាព និងគុណភាពនៃការគ្រប់គ្រងមណ្ឌលថែទាំកុមារ ដោយផ្តោតលើគុណភាពសេវាការគ្រប់គ្រងករណី ការធ្វើអធិការកិច្ចកន្លែង ឬមណ្ឌលថែទាំកុមារ និងការថែទាំកុមារតាមសហគមន៍ឱ្យស្របតាមគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ
- បន្តលើកកម្ពស់សេវាថែទាំ និងគុណភាពការថែទាំកុមារតាមគ្រួសារនិងសហគមន៍ ដោយប្រមូលផ្តុំលើ ការពង្រឹងពង្រីកកម្មវិធីការបង្រួបបង្រួមគ្រួសារ ការបង្វែរ និងសមាហរណកម្មកុមារពីមណ្ឌលទៅជាការថែទាំនៅតាមគ្រួសារនិងសហមគន៍ រួមទាំងការថែទាំដោយឪពុកម្តាយធម៌ ការថែទាំដោយសាច់ញាតិ និងសុំកូនក្នុងប្រទេស
- បន្តត្រួតពិនិត្យ និងវាយតម្លៃគុណភាពសេវាដែលបានផ្តល់សេវាដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តមុខងារដែលបានផ្ទេរ
- សម្របសម្រួល និងតាមដានការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ
- តាមដានការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ
- ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងរបាយការណ៍ស្តីពីស្ថានភាពកុមារ ដោយប្រមូលផ្តុំលើ ការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ផែនការសកម្មភាពដើម្បី

បង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ សំដៅលើកកម្ពស់សិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ

- ជំរុញនិងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ តាមរយៈ ការផ្សព្វផ្សាយអនុសញ្ញា ស្តីពីសិទ្ធិកុមារ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសិទ្ធិនិងការការពារកុមារ ការពង្រឹងសមត្ថភាពមន្ត្រីរដ្ឋាភិបាលនិងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលឱ្យបានទូលំទូលាយ និងច្បាប់ស្តីពីកិច្ចការពារកុមារនៅកម្ពុជា
- បន្តអនុវត្តគម្រោង "យុទ្ធនាការផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុមកលើស្ត្រី និងកុមារក្នុងតំបន់អាស៊ាន"
- អនុវត្តកាតព្វកិច្ចក្នុងនាមជាសមាជិកនៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ តាមរយៈការរៀបចំរបាយការណ៍ជាតិ ស្តីពីការអនុវត្តសិទ្ធិកុមារ របាយការណ៍ ស្តីពីការអនុវត្តពិធីសារបន្ថែម និងការរៀបចំទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា
- អនុវត្តការងារសុំកូនអន្តរប្រទេសដោយធានាឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ដោយប្រមូលផ្តុំលើការផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលមានវិជ្ជាជីវៈ និងក្រមសីលធម៌ក្នុងការធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ការផ្សព្វផ្សាយនិងការបណ្តុះបណ្តាល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ស្តីពីសុំកូនអន្តរប្រទេសដល់អ្នកពាក់ព័ន្ធ
- ផ្តល់សេវាស្តារនីតិសម្បទាអនីតិជនដែលទំនាស់នឹងច្បាប់ ដោយប្រមូលផ្តុំលើ ការដាក់ឱ្យដំណើរការមណ្ឌលយុវនីតិសម្បទា ការទទួលអនីតិជនទំនាស់នឹងច្បាប់ ការរៀបចំកម្មវិធីបណ្តុះបណ្តាលបំណិនជីវិតនិងជំនាញវិជ្ជាជីវៈដល់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ការផ្សព្វផ្សាយ អប់រំកុមារ យុវជន ទប់ស្កាត់បាតុភាពអសកម្មនានាក្នុងសង្គម
- រៀបចំនិងដាក់ឱ្យអនុវត្តនូវគោលការណ៍សម្រាប់ការអនុវត្តផែនការបង្វែរ និងរចនាសម្ព័ន្ធភ្នាក់ងារសង្គមកិច្ចពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន ព្រមទាំងការផ្តល់សេវាសង្គមកិច្ចគាំពារដល់កុមារតាមម្តាយក្នុងពន្ធនាគារ
- ផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ដោយប្រមូលផ្តុំលើ ការទទួល ព្យាបាល បន្សាប ស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅក្នុងមណ្ឌល និងលើកទឹកចិត្តការព្យាបាលនិងស្តារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀននៅតាមសហគមន៍ ដោយមានការចូលរួមទទួលខុសត្រូវ របស់ឪពុកម្តាយនិងសាច់ញាតិ។

**អនុកម្មវិធីទី១.៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ**

- បង្កើនប្រសិទ្ធភាពផ្តល់សេវាសុខុមាលភាពជនពិការ និងលើកកម្ពស់សិទ្ធិជនពិការ ដោយប្រមូលផ្តុំលើ ការរៀបចំប្រព័ន្ធទិន្នន័យគ្រប់គ្រងជនពិការឱ្យបានច្បាស់លាស់ បណ្តុះបណ្តាលវិជ្ជាជីវៈនិងបង្កើតមុខរបរដល់ជនពិការ សម្របសម្រួលនិងជំរុញឱ្យក្រសួង ស្ថាប័នរដ្ឋ និងសហគ្រាសឯកជនអនុវត្តកាតព្វកិច្ចទទួលជនពិការចូលបម្រើការងារ និងរៀបចំលក្ខណៈងាយស្រួល សម្រាប់ជនពិការបំលាស់ទី និងលើកទឹកចិត្តចលនាកីឡា សិល្បៈរបស់ជនពិការ
- ពង្រឹងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ យុទ្ធសាស្ត្រជាតិស្តីពីពិការភាព និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត តាមរយៈ ការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ២០១៩-២០២៣ ការធ្វើវិសោធនកម្មច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ការផ្តល់សេវាផ្លូវច្បាប់សម្រាប់ជនពិការដោយសហការជាមួយស្ថាប័នតុលាការ មន្ត្រីយុត្តិធម៌ និងបុគ្គលិកពន្ធនាគារ ការរៀបចំរបាយការណ៍នៃការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ និងពិធីសារបន្ថែម ការពង្រឹងយន្តការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ ការរៀបចំទិវាជនពិការជាតិ អន្តរជាតិ និងទិវាផ្សេងៗពាក់ព័ន្ធជនពិការ ការអនុវត្តស្តង់ដាអប្បបរមានៃការបង្កលក្ខណៈងាយស្រួលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មធ្យោបាយធ្វើដំណើរ និងទំនាក់ទំនងសម្រាប់ជនពិការ ការបញ្ជ្រាបការយល់ដឹងអំពីសមត្ថភាពបើកបរនិងផ្តល់ប័ណ្ណបើកបរសម្រាប់ជនពិការ និងការផ្សព្វផ្សាយលិខិត បទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងពិការភាព។

**អនុកម្មវិធីទី១.៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់**

- ពង្រឹងសកម្មភាពសមាគមមនុស្សចាស់ តាមឃុំ សង្កាត់ ដោយប្រមូលផ្តុំលើ ការផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សមាគមមនុស្សចាស់ ការពង្រឹងសមត្ថភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់និងអនុគណៈកម្មាធិការដើម្បីមនុស្សចាស់ថ្នាក់រាជធានី ខេត្ត និងការកែសម្រួលលក្ខន្តិកៈសមាគមមនុស្សចាស់និងគោលការណ៍ណែនាំ ស្តីពីការបង្កើត និងគ្រប់គ្រងសមាគមមនុស្សចាស់

- ជំរុញអនុវត្តគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ តាមរយៈការរៀបចំនិងអនុវត្តផែនការសកម្មភាព ២០២១-២០២៥នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ ការរៀបចំលិខិតបទដ្ឋានគតិយុត្តការដាក់ឱ្យដំណើរការមជ្ឈមណ្ឌលជាតិគាំពារមនុស្សវ័យចាស់សំដៅបណ្តុះបណ្តាលវិជ្ជាជីវៈថែទាំមនុស្សចាស់ សម្រាប់អ្នកថែទាំ អ្នកធ្វើកិច្ចការសង្គម និងអ្នកស្ម័គ្រចិត្ត។

**អនុកម្មវិធីទី១.៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន**

- អភិវឌ្ឍសហគមន៍អតីតយុទ្ធជន ដោយប្រមូលផ្តុំលើ ការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជនឃុំ សង្កាត់ និងការបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីនីតិវិធីប្រមូលទិន្នន័យពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារ នៅតាមឃុំ សង្កាត់ សំដៅកែលម្អ និងទ្រទ្រង់ជីវភាពអតីតយុទ្ធជន និងគ្រួសារ
- សម្របសម្រួលការងារសមាគមអតីតយុទ្ធជននៅថ្នាក់ឃុំ សង្កាត់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយសមាគមអតីតយុទ្ធជនកម្ពុជា ដើម្បីពង្រឹងការអនុវត្តបេឡាមរណសង្គ្រោះ ការសាងសង់ផ្ទះ ការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន និងការរៀបចំទិវាអតីតយុទ្ធជនកម្ពុជា ២១មិថុនា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**កម្មវិធីទី២. ការបង្កើនប្រសិទ្ធិភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ**

**អនុកម្មវិធីទី២.១. ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល**

- ផ្តល់របបសន្តិសុខសង្គមជូនសិទ្ធិវន្តនៃ ប.ជ.ស. តាមរយៈ ការបើកផ្តល់របបសន្តិសុខសង្គមជូននិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក បានទាន់ពេលវេលា និងការបង្កើតយន្តការសិក្សាស្រាវជ្រាវដើម្បីកាត់បន្ថយគម្លាតនៃរបបសោធនរបស់មន្ត្រីសាធារណៈ
- សហការជាមួយបេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស. ដើម្បីផ្តល់សេវាធានារ៉ាប់រងសុខភាពសម្រាប់អតីតមន្ត្រីរាជការស៊ីវិល
- ពន្លឿនការបើកផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួសារសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងបន្តផ្ទេរសិទ្ធិជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលមានជំងឺមិនអាចទៅបើកប្រាក់សោធនប្រចាំខែនៅតាមធនាគារ។

**អនុកម្មវិធីទី២.២.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ**

- បង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ដោយប្រមូលផ្តុំលើ ការបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជននិងអ្នកនៅក្នុងបន្ទុក និងប្រាក់គោលនយោបាយមរណភាពជូនដល់គ្រួសារអតីតយុទ្ធជនឱ្យបានទាន់ពេលវេលា ការធ្វើបច្ចុប្បន្នភាពអតីតយុទ្ធជន និងការចេញលិខិតផ្ទេរសិទ្ធិបើកប្រាក់របបសន្តិសុខសង្គមប្រចាំខែជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន
- បន្តកែសម្រួលរបបសន្តិសុខសង្គម តាមរយៈការកាត់បន្ថយគម្លាតនៃរបបសោធនរបស់នគរបាលជាតិ និងយោធិននៃកងយោធពលខេមរភូមិន្ទ និងការបង្កើនប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងអ្នកនៅក្នុងបន្ទុក។

**អនុកម្មវិធីទី២.៣.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ**

- ផ្តល់សេវាស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទជូនជនពិការ ដោយប្រមូលផ្តុំលើ ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ការផ្តល់សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ ការផ្តល់សេវាតាមសហគមន៍សម្រាប់ជនពិការ និងការផលិតឧបករណ៍សិប្បនិម្មិត និងឈើច្រត់
- កៀរគរប្រភពធនធានថវិកាសម្រាប់និរន្តរភាពសេវាស្តារលទ្ធភាពពលកម្មជូនជនពិការ។ ការប្រមូលភាគទានប្រាក់ពិន័យអន្តរការណ៍ចំពោះស្ថាប័ននានា និងនីតិបុគ្គលដែលមិនបានបំពេញកាតព្វកិច្ច ដូចមានចែងក្នុងច្បាប់ ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ការពង្រីកការដាក់ហិបមូលនិធិជនពិការនៅតាមរាជធានី ខេត្ត ការផ្តល់សេវាព្យាបាលដោយចលនាដោយបង់ប្រាក់ និងការសហប្រតិបត្តិការជាមួយអង្គការដៃគូនានា
- ផ្តល់របបគោលនយោបាយឧបត្ថម្ភដល់ជនពិការ ដោយប្រមូលផ្តុំលើ ការផ្តល់របបគោលនយោបាយថ្លៃធ្វើដំណើរ និងអាហារដល់ជនពិការ ដែលមកទទួលសេវាព្យាបាលនៅតាមមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម និងការអនុវត្តការបើកផ្តល់របបគោលនយោបាយថែទាំសុខភាពជូនជនពិការក្រីក្រនៅសហគមន៍
- ផ្តល់ការគាំទ្រលើជីវភាពដល់ជនពិការក្រីក្រតាមរយៈការសាងសង់ផ្ទះជូន និងផ្តល់ប្រាក់កម្ចីសម្រាប់អភិវឌ្ឍមុខរបរ។

**កម្មវិធីទី៣ ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូ**

**អនុកម្មវិធីទី៣.១.ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងភាពជាដៃគូ**

- ពង្រឹងសមត្ថភាពមន្ត្រីរាជការ និងបង្កើនប្រសិទ្ធភាពការងារ ដោយប្រមូលផ្តុំលើ ការពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី តាមរយៈ ការអនុវត្តច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល បទបញ្ជាផ្ទៃក្នុង និងរបៀបរបបធ្វើការឱ្យបានហ្មឹងម៉ាត់
- លើកទឹកចិត្តមន្ត្រីគ្រប់លំដាប់ថ្នាក់ តាមរយៈការដំឡើង ឋានៈ តួនាទី ឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗ
- ពង្រឹងការងារផែនការ និងផ្សព្វផ្សាយ តាមរយៈ ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ការពិនិត្យនិងវាយតម្លៃការអនុវត្តសកម្មភាពនិងលទ្ធផលការងាររបស់អង្គភាពចំណុះ និងមន្ទីរ ស.អ.យ. រាជធានី ខេត្ត ការផ្សព្វផ្សាយលទ្ធផលការងារដែលសម្រេចបាន និងការពង្រឹងប្រព័ន្ធស្ថិតិ
- បន្តអនុវត្តកម្មវិធីកំណែទម្រង់នានារបស់រដ្ឋ រួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈ ការដាក់ឲ្យប្រើប្រាស់ពេញលេញមុខងារ FMIS ប្រព័ន្ធព្យាករណ៍សាច់ប្រាក់ CMS ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ SAMIS និងការដាក់ឲ្យប្រើប្រាស់នូវសៀវភៅគោលការណ៍ណែនាំស្តីពីការរៀបចំនិងការអនុវត្តថវិកា MoSVY-FMM ដើម្បីធានាបាននូវតម្លាភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រសួងស.អ.យ
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងអន្តរជាតិ ដើម្បីកៀរគរធនធានបម្រើឱ្យតម្រូវការ និងសំណូមពររបស់ជនរងគ្រោះនិងងាយរងគ្រោះគ្រប់ប្រភេទ និងពង្រឹងពង្រីកទំនាក់ទំនងសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសនានា ក្នុងតំបន់អាស៊ាន និងសាកលលោក
- ពង្រឹងការងារអធិការកិច្ច ដោយប្រមូលផ្តុំលើ ការធ្វើអធិការកិច្ច អង្គភាព មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត លើការអនុវត្តបទបញ្ជាផ្ទៃក្នុង របៀបរបបការងារ និងការគ្រប់គ្រងវត្តមានរបស់មន្ត្រី និងការដោះស្រាយបណ្តឹងនិងវិវាទការងារជូនមន្ត្រីរាជការរបស់ក្រសួងប្រកបដោយយុត្តិធម៌
- បន្តធ្វើសវនកម្មនៅតាមអង្គភាព និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្តលើការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋ។

**អនុកម្មវិធីទី៣.២.ការអភិវឌ្ឍធនធានមនុស្ស**

- បន្តបណ្តុះបណ្តាលវិជ្ជាជីវៈកម្រិតឧត្តមសិក្សា និងកម្រិតវិញ្ញាបនបត្រ ដោយប្រមូលផ្តុំលើ ការបណ្តុះបណ្តាលវិជ្ជាជីវៈកម្រិត ថ្នាក់បរិញ្ញាបត្រ សង្គមកិច្ច សង្គមវិទ្យា កិច្ចគាំពារសង្គម គ្រប់គ្រងសាធារណៈ រដ្ឋបាលសាធារណៈ គោលនយោបាយសង្គម គោលនយោបាយសាធារណៈ អក្សរសាស្ត្រអង់គ្លេស និងបរិញ្ញាបត្រវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណប និងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈជំនាញសង្គមកិច្ច(កម្រិត១ កម្រិត២ កម្រិត៣ និងកម្រិត៤) និងការបណ្តុះបណ្តាលរយៈពេលខ្លីកម្រិតវិញ្ញាបនបត្រលើមុខជំនាញផ្សេងៗ
- បន្តក្នុងការអនុវត្តនូវសកម្មភាពផែនការយុទ្ធសាស្ត្រសម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម ដោយផ្តោតលើកិច្ចការពារកុមារ ឆ្នាំ២០២១-២០២៥
- បន្តពង្រឹង និងពង្រីកសមត្ថភាពវិទ្យាស្ថានជាតិសង្គមកិច្ច ដោយប្រមូលផ្តុំលើ ការជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាព ការរៀបចំផែនការបណ្តុះបណ្តាល ការអភិវឌ្ឍកម្មវិធីសិក្សា ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការបំពាក់បរិក្ខារសិក្សាសមរម្យ៕

ថ្ងៃ ចន្ទ ១២កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**វង សូត**

# តារាងឧបសម្ព័ន្ធ

## ម៉ាទ្រិចស្តីពីការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធី

| ល.រ | សូចនាករ | ឯកតា | ២០២១ | ប្រភពទិន្នន័យ |
|---|---|---|---|---|
| ១ | គ្រួសាររងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះមហន្តរាយ នៅតាមសហគមន៍ បានទទួលជំនួយសង្គ្រោះបន្ទាន់ | គ្រួសារ | ៣២ ៨៤១ | MAIS[3] ( MoSVY ) |
| ២ | ជនអនាថាដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ៥៤១ | MAIS( MoSVY ) |
| ៣ | ជនអនាថាដែលទទួលបានសេវាគាំពារ | នាក់ | ១ ២៩៥ | MAIS( MoSVY ) |
| ៤ | ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារផ្ទុកមេរោគអេដស៍ជំងឺអេដស៍ដែលទទួលសេវាថែទាំគាំទ្រតាមសហគមន៍ | នាក់ | ៣៣១ | MAIS( MoSVY ) |
| ៥ | ជនវិបល្លាសស្មារតីទទួលបានសេវាព្យាបាល និងថែទាំ ក្នុងមជ្ឈមណ្ឌល | នាក់ | ៧០ | MAIS( MoSVY ) |
| ៦ | ស្ត្រីមានផ្ទៃពោះនៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | ៣៧ ៨២៦ | CTP-MIS[4] |
| ៧ | កុមារអាយុ ០-២ឆ្នាំ នៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | ៤ ៩១៣ | CTP-MIS |
| ៨ | ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភទទួលបានការស្តារនីតិសម្បទា | នាក់ | ១ ៨០៨ | MAIS( MoSVY ) |
| ៩ | ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដែលត្រូវបានគាំពារ និងជួយសង្គ្រោះ | នាក់ | ០ | MAIS( MoSVY ) |
| ១០ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសខ្លួនវិញ | នាក់ | ៥ | MAIS( MoSVY ) |
| ១១ | ជនរងគ្រោះដោយអំពើជួញដូរបានធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេស | នាក់ | ៤០៤ | MAIS( MoSVY ) |
| ១២ | ជនរងគ្រោះដោយអំពើជួញដូរបានធ្វើសមាហរណកម្មទៅតាមសហគមន៍វិញ | នាក់ | ៣១៧ | MAIS( MoSVY ) |
| ១៣ | ជនរងគ្រោះដោយអំពើជួញដូរត្រូវបានផ្តល់សេវាក្រោយធ្វើសមាហរណកម្ម | នាក់ | ៥៧ | MAIS( MoSVY ) |
| ១៤ | ជនរងគ្រោះដោយអំពើជួញដូរត្រូវបានបិទករណី | នាក់ | ៨០ | MAIS( MoSVY ) |
| ១៥ | កុមារកំព្រា និង កុមារងាយរងគ្រោះដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ | នាក់ | ៥ ៤៤០ | MAIS( MoSVY ) |
| ១៦ | កុមារកំព្រា និង កុមារងាយរងគ្រោះដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ១ ១៤៤៧ | MAIS( MoSVY ) |
| ១៧ | កុមាររងគ្រោះដែលទទួលបានថែទាំដោយក្រុមគ្រួសារ និងសហគមន៍ | នាក់ | ១ ៨៨១ | MAIS( MoSVY ) |
| ១៨ | កុមារដែលត្រូវបានសុំកូនអន្តរប្រទេស | នាក់ | ០ | MAIS( MoSVY ) |
| ១៩ | ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលទទួលបានការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស | ទីភ្នាក់ងារ | ០ | MAIS( MoSVY ) |
| ២០ | អនីតិជនប្រព្រឹត្តល្មើសច្បាប់ដែលជាប់ក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ និងមណ្ឌលយុវនីតិសម្បទាទទួលបានសេវាស្តារនីតិសម្បទា | នាក់ | ១ ២៨៣ | MAIS( MoSVY ) |

[3] ប្រព័ន្ធព័ត៌មានរដ្ឋបាលរបស់ក្រសួង

[4] Cash Transfer Program-Management Information System

| | | | | |
|---|---|---|---|---|
| ២១ | កូនតាមម្ដាយដែលមានអាយុចាប់ពី៣ឆ្នាំឡើងទៅ នៅក្នុងពន្ធនាគារ ត្រូវបានទទួលសេវាសង្គមកិច្ច | នាក់ | ១០ | MAIS( MoSVY ) |
| ២២ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានស្តារនីតិសម្បទា | នាក់ | ៩ ៩៦៨ | MAIS( MoSVY ) |
| ២៣ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ៦ ៩៧០ | MAIS( MoSVY ) |
| ២៤ | ជនពិការដែលទទួលបានសេវាស្ដារលទ្ធភាពពលកម្មកាយសម្បទានៅតាមមជ្ឈមណ្ឌល | នាក់ | ១២ ៦១៧ | PM4[5] ( MoSVY ) |
| ២៥ | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ | នាក់ | ២០ ៧០១ | PM4 ( MoSVY ) |
| ២៦ | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍ | នាក់ | ៣ ៤៤៦ | MAIS( MoSVY ) |
| ២៧ | ជនពិការក្រីក្រទទួលបានរបបគោលនយោបាយឧបត្ថម្ភ និងសេវាពិនិត្យថែទាំសុខភាព | នាក់ | ៩ ២៥២ | MAIS( MoSVY ) |
| ២៨ | ជនពិការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ | នាក់ | ៣៥ | MAIS( MoSVY ) |
| ២៩ | ជនពិការត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័នរដ្ឋ (២%) | នាក់ | ៣ ៦២១ | MAIS( MoSVY ) |
| ៣០ | ជនពិការត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័នឯកជន(១%) | នាក់ | ៥ ២៣៥ | MAIS( MoSVY ) |
| ៣១ | ជនពិការក្រីក្រនៅតាមសហគមន៍ទទួលបានរបបឧបត្ថម្ភគោលនយោបាយ | នាក់ | ១៦ ៨០២ | MAIS( MoSVY ) |
| ៣២ | អត្រាមនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំនៅតាមសហគមន៍ | នាក់ | - | MAIS( MoSVY ) |
| ៣៣ | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំក្នុងមជ្ឈមណ្ឌលគាំពារមនុស្សចាស់ | នាក់ | - | MAIS( MoSVY ) |
| ៣៤ | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានគោលរបបគាំពារសង្គម | នាក់ | ៣៣៨ ០៧៦ | MAIS( MoSVY ) |
| ៣៥ | និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុកដែលទទួលរបបសន្តិសុខសង្គម | នាក់ | ១០២ ២៩២ | RID[6] ( NSSFC[7] ) |
| | និវត្តជនដែលទទួលរបបសោធន | % | ៥៦ ២៤១ | |
| | ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលរបបសោធន | នាក់ | ១ ៨៤៧ | |
| | អ្នកនៅក្នុងបន្ទុក | នាក់ | ៤៤ ៨៤១ | |
| ៣៦ | អតីតយុទ្ធជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ១០២ ៦២៨ | VDS[8] ( NFV[9] ) |
| | និវត្តជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ៣៦ ២១១ | |
| | ជនបាត់បង់សមត្ថភាពការងារដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ១ ៤៧៤ | |
| | ជនពិការដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៨ ៦៨៧ | |

[5] Partient Management Version 4th

[6] Retiree Invalidity Database ប្រព័ន្ធទិន្នន័យគ្រប់គ្រងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ

[7] National Social Security Fund for Civil Servants បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

[8] Veterans Database System ប្រព័ន្ធទិន្នន័យគ្រប់គ្រងអតីតយុទ្ធជន

[9] National Fund for Veterans បេឡាជាតិអតីតយុទ្ធជន

| | | | | |
|---|---|---|---|---|
| | ជនពលីដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៦ ៨២៩ | |
| | ជនមរណៈដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ៩ ៤២៧ | |
| ៣៧ | និស្សិតដែលបានចុះឈ្មោះចូលរៀនឆ្នាំទី១ | នាក់ | ៩២ | MAIS( MoSVY ) |
| ៣៨ | និស្សិតដែលកំពុងសិក្សាកម្រិតបរិញ្ញាបត្រ | នាក់ | ៤៦៣ | MAIS( MoSVY ) |
| ៣៩ | និស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ | នាក់ | ៧០ | MAIS( MoSVY ) |
| ៤០ | សិក្ខាកាមដែលបានបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រ | នាក់ | ៥៨ | MAIS( MoSVY ) |

គ្រួសារក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ទទួលការឧបត្ថម្ភសាច់ប្រាក់ពីកម្មវិធី បែងចែកតាមតំបន់

| ល.រ | លេខកូដតំបន់ | ឈ្មោះតំបន់ | ឯកតា | ២០២១ |
|---|---|---|---|---|
| ១ | 004KHM001 | បន្ទាយមានជ័យ | នាក់ | ៣១ ៥០៤ |
| ២ | 004KHM002 | បាត់ដំបង | នាក់ | ៨៩ ៥៥៨ |
| ៣ | 004KHM003 | កំពង់ចាម | នាក់ | ៤៧ ៣៨៤ |
| ៤ | 004KHM004 | កំពង់ឆ្នាំង | នាក់ | ២៧ ៥២៧ |
| ៥ | 004KHM005 | កំពង់ស្ពឺ | នាក់ | ២៣ ០៦១ |
| ៦ | 004KHM006 | កំពង់ធំ | នាក់ | ៤១ ៨២០ |
| ៧ | 004KHM007 | កំពត | នាក់ | ២៤ ២៦០ |
| ៨ | 004KHM008 | កណ្តាល | នាក់ | ៣៥ ៥៧៩ |
| ៩ | 004KHM009 | កោះកុង | នាក់ | ៨ ៣៨២ |
| ១០ | 004KHM010 | ក្រចេះ | នាក់ | ២៧ ៣១១ |
| ១១ | 004KHM011 | មណ្ឌលគិរី | នាក់ | ៤ ៤១៩ |
| ១២ | 004KHM012 | ភ្នំពេញ | នាក់ | ៣២ ៣៦០ |
| ១៣ | 004KHM013 | ព្រះវិហារ | នាក់ | ១៤ ៤៣៧ |
| ១៤ | 004KHM014 | ព្រៃវែង | នាក់ | ៥០ ៥៨៧ |
| ១៥ | 004KHM015 | ពោធិ៍សាត់ | នាក់ | ២៧ ៥៤៩ |
| ១៦ | 004KHM016 | រតនគិរី | នាក់ | ១៤ ៥២៣ |
| ១៧ | 004KHM017 | សៀមរាប | នាក់ | ៤៧ ៣០២ |
| ១៨ | 004KHM018 | ព្រះសីហនុ | នាក់ | ៥ ២៩៥ |
| ១៩ | 004KHM019 | ស្ទឹងត្រែង | នាក់ | ៩ ៧៤៩ |
| ២០ | 004KHM020 | ស្វាយរៀង | នាក់ | ២២ ៥២៧ |
| ២១ | 004KHM021 | តាកែវ | នាក់ | ៣៨ ៦៤៤ |
| ២២ | 004KHM022 | ឧត្តរមានជ័យ | នាក់ | ១១ ៤២៩ |
| ២៣ | 004KHM023 | កែប | នាក់ | ១ ៧៧៥ |
| ២៤ | 004KHM024 | ប៉ៃលិន | នាក់ | ៥ ៥៤៤ |
| ២៥ | 004KHM025 | ត្បូងឃ្មុំ | នាក់ | ៣៩ ៨៤៤ |
| | សរុប | | នាក់ | ៦៨២ ៣២៨ |

អតីតមន្ត្រីរាជការស៊ីវិលខេត្ត ឆ្នាំ២០២១ បែងចែកតាមតំបន់

| ល.រ | លេខកូដតំបន់ | ឈ្មោះតំបន់ | ឯកតា | ២០២១ |
|---|---|---|---|---|
| ១ | 004KHM001 | បន្ទាយមានជ័យ | នាក់ | ១ ៦៣០ |
| ២ | 004KHM002 | បាត់ដំបង | នាក់ | ៣ ៥៥១ |
| ៣ | 004KHM003 | កំពង់ចាម | នាក់ | ៣ ០៨៦ |
| ៤ | 004KHM004 | កំពង់ឆ្នាំង | នាក់ | ១ ៦៧៤ |
| ៥ | 004KHM005 | កំពង់ស្ពឺ | នាក់ | ២ ២៥៨ |
| ៦ | 004KHM006 | កំពង់ធំ | នាក់ | ២ ០៤៦ |
| ៧ | 004KHM007 | កំពត | នាក់ | ២ ៤០២ |
| ៨ | 004KHM008 | កណ្តាល | នាក់ | ៤ ៧៩១ |
| ៩ | 004KHM009 | កោះកុង | នាក់ | ៣៥៥ |
| ១០ | 004KHM010 | ក្រចេះ | នាក់ | ១ ០៧៨ |
| ១១ | 004KHM011 | មណ្ឌលគិរី | នាក់ | ១៧២ |
| ១២ | 004KHM012 | ភ្នំពេញ | នាក់ | ១៧ ១៤៧ |
| ១៣ | 004KHM013 | ព្រះវិហារ | នាក់ | ៥៤៣ |
| ១៤ | 004KHM014 | ព្រៃវែង | នាក់ | ៣ ៧០៨ |
| ១៥ | 004KHM015 | ពោធិ៍សាត់ | នាក់ | ១ ៦២៧ |
| ១៦ | 004KHM016 | រតនគិរី | នាក់ | ៣៨៤ |
| ១៧ | 004KHM017 | សៀមរាប | នាក់ | ២ ០៦៤ |
| ១៨ | 004KHM018 | ព្រះសីហនុ | នាក់ | ៧៨៧ |
| ១៩ | 004KHM019 | ស្ទឹងត្រែង | នាក់ | ៣៩០ |
| ២០ | 004KHM020 | ស្វាយរៀង | នាក់ | ២ ០០៦ |
| ២១ | 004KHM021 | តាកែវ | នាក់ | ៣ ១៤៨ |
| ២២ | 004KHM022 | ឧត្តរមានជ័យ | នាក់ | ៣៥២ |
| ២៣ | 004KHM023 | កែប | នាក់ | ៧៩ |
| ២៤ | 004KHM024 | ប៉ៃលិន | នាក់ | ២៩៣ |
| ២៥ | 004KHM025 | ត្បូងឃ្មុំ | នាក់ | ១ ៧៩៧ |
| | **សរុប** | | **នាក់** | **៥៨ ០៨៨** |

អតីតយុទ្ធជនខែជូ ឆ្នាំ២០២១ បែងចែកតាមតំបន់

| ល.រ | លេខកូដតំបន់ | ឈ្មោះតំបន់ | ឯកតា | ២០២១ |
|---|---|---|---|---|
| ១ | 004KHM001 | បន្ទាយមានជ័យ | នាក់ | ៦ ២៧១ |
| ២ | 004KHM002 | បាត់ដំបង | នាក់ | ១៣ ២៨១ |
| ៣ | 004KHM003 | កំពង់ចាម | នាក់ | ៣ ៦១៧ |
| ៤ | 004KHM004 | កំពង់ឆ្នាំង | នាក់ | ៣ ៧៩៤ |
| ៥ | 004KHM005 | កំពង់ស្ពឺ | នាក់ | ៦ ១៨០ |
| ៦ | 004KHM006 | កំពង់ធំ | នាក់ | ៣ ៧៦២ |
| ៧ | 004KHM007 | កំពត | នាក់ | ៥ ១៧៩ |
| ៨ | 004KHM008 | កណ្ដាល | នាក់ | ៥ ១១៧ |
| ៩ | 004KHM009 | កោះកុង | នាក់ | ៩៥៥ |
| ១០ | 004KHM010 | ក្រចេះ | នាក់ | ១ ៤៩២ |
| ១១ | 004KHM011 | មណ្ឌលគិរី | នាក់ | ៣៨៦ |
| ១២ | 004KHM012 | ភ្នំពេញ | នាក់ | ១១ ៨៨៧ |
| ១៣ | 004KHM013 | ព្រះវិហារ | នាក់ | ២ ៦១៣ |
| ១៤ | 004KHM014 | ព្រៃវែង | នាក់ | ៤ ៤៥៦ |
| ១៥ | 004KHM015 | ពោធិ៍សាត់ | នាក់ | ៤ ៩៥២ |
| ១៦ | 004KHM016 | រតនគិរី | នាក់ | ៧១៦ |
| ១៧ | 004KHM017 | សៀមរាប | នាក់ | ៨ ៦០១ |
| ១៨ | 004KHM018 | ព្រះសីហនុ | នាក់ | ១ ២៦៤ |
| ១៩ | 004KHM019 | ស្ទឹងត្រែង | នាក់ | ១ ២៤០ |
| ២០ | 004KHM020 | ស្វាយរៀង | នាក់ | ៣ ៣៧១ |
| ២១ | 004KHM021 | តាកែវ | នាក់ | ៤ ៦៣៦ |
| ២២ | 004KHM022 | ឧត្ដរមានជ័យ | នាក់ | ៤ ០៤៩ |
| ២៣ | 004KHM023 | កែប | នាក់ | ៣៣៧ |
| ២៤ | 004KHM024 | ប៉ៃលិន | នាក់ | ១ ៧៣៨ |
| ២៥ | 004KHM025 | ត្បូងឃ្មុំ | នាក់ | ២ ៧៣៤ |
| | **សរុប** | | | **១០២ ៦២៨** |

ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទាតាមតំបន់ និងភេទ

| ល.រ | កូដតំបន់ | ឈ្មោះតំបន់ | ឈ្មោះមណ្ឌលស្តារ | ឯកតា | ២០២១ | |
|---|---|---|---|---|---|---|
| | | | | | ស្រី | សរុប |
| ១ | 004KHM002 | បាត់ដំបង | មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តបាត់ដំបង | នាក់ | ៨៣៥ | ៣ ៩៦២ |
| ២ | 004KHM003 | កំពង់ចាម | មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ចាម | នាក់ | ៥១៦ | ១ ៣១១ |
| ៣ | 004KHM004 | កំពង់ឆ្នាំង | មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ឆ្នាំង | នាក់ | ២៥០ | ៨៦៤ |
| ៤ | 004KHM005 | កំពង់ស្ពឺ | មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ស្ពឺ | នាក់ | ៤៥២ | ១ ៨១៥ |
| ៥ | 004KHM006 | កំពង់ធំ | មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ធំ | នាក់ | ១៤២ | ៦៧០ |
| ៦ | 004KHM010 | ក្រចេះ | មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តក្រចេះ | នាក់ | ៥៤ | ២៥៦ |
| ៧ | 004KHM012 | ភ្នំពេញ | មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តគៀនឃ្លាំង | នាក់ | ៣១១ | ៨៣៣ |
| | | | មហាវិទ្យាល័យស្វែកម្មឧបករណ៍សិប្បនិម្មិត និងរណប | | ៣៤៧ | ១ ០០៨ |
| ៨ | 004KHM013 | ព្រះវិហារ | មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តព្រះវិហារ | នាក់ | ៨ | ៤៨ |
| ៩ | 004KHM014 | ព្រៃវែង | មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តព្រៃវែង | នាក់ | ១២០ | ៥៤២ |
| ១០ | 004KHM017 | សៀមរាប | មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តសៀមរាប | នាក់ | ៤ | ១៧១ |
| ១១ | 004KHM018 | ព្រះសីហនុ | មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តព្រះសីហនុ | នាក់ | ៩៤ | ៤០៧ |
| ១២ | 004KHM020 | ស្វាយរៀង | ស្វាយរៀង | នាក់ | ២ | ៩២ |
| ១៣ | 004KHM021 | តាកែវ | មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តតាកែវ | នាក់ | ១០៦ | ៦៣៨ |
| | **សរុប** | | | **នាក់** | **៣ ២៤១** | **១២ ៦១៧** |

## កុមារកំព្រា និងកុមារងាយរងគ្រោះដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ បែងចែកតាមតំបន់

| ល.រ | លេខកូដតំបន់ | ឈ្មោះតំបន់ | ចំនួនមណ្ឌលថែទាំកុមារ | ឯកតា | ២០២១ |
|---|---|---|---|---|---|
| ១ | 004KHM001 | បន្ទាយមានជ័យ | ២១ | នាក់ | ៣៣៧ |
| ២ | 004KHM002 | បាត់ដំបង | ១៧ | នាក់ | ៥៧៩ |
| ៣ | 004KHM003 | កំពង់ចាម | ៣ | នាក់ | ១១១ |
| ៤ | 004KHM004 | កំពង់ឆ្នាំង | ១១ | នាក់ | ១២៨ |
| ៥ | 004KHM005 | កំពង់ស្ពឺ | ១០ | នាក់ | ២៧៩ |
| ៦ | 004KHM006 | កំពង់ធំ | ៩ | នាក់ | ២៥៩ |
| ៧ | 004KHM007 | កំពត | ៥ | នាក់ | ១៥០ |
| ៨ | 004KHM008 | កណ្ដាល | ១៦ | នាក់ | ៥៦០ |
| ៩ | 004KHM009 | កោះកុង | ១ | នាក់ | ២ |
| ១០ | 004KHM010 | ក្រចេះ | ១ | នាក់ | ៨០ |
| ១១ | 004KHM011 | មណ្ឌលគិរី | ១ | នាក់ | ១៨ |
| ១២ | 004KHM012 | ភ្នំពេញ | ៤៤ | នាក់ | ១ ៥៩៤ |
| ១៣ | 004KHM013 | ព្រះវិហារ | ៣ | នាក់ | ៨៩ |
| ១៤ | 004KHM014 | ព្រៃវែង | ៥ | នាក់ | ១៥២ |
| ១៥ | 004KHM015 | ពោធិ៍សាត់ | ៣ | នាក់ | ១០៧ |
| ១៦ | 004KHM016 | រតនគិរី | ២ | នាក់ | ៨២ |
| ១៧ | 004KHM017 | សៀមរាប | ២៨ | នាក់ | ៤៥០ |
| ១៨ | 004KHM018 | ព្រះសីហនុ | ៤ | នាក់ | ៣៩ |
| ១៩ | 004KHM019 | ស្ទឹងត្រែង | ១ | នាក់ | ១០ |
| ២០ | 004KHM020 | ស្វាយរៀង | ១ | នាក់ | ២៦ |
| ២១ | 004KHM021 | តាកែវ | ៥ | នាក់ | ១៤២ |
| ២២ | 004KHM022 | ឧត្ដរមានជ័យ | ២ | នាក់ | ៩៥ |
| ២៣ | 004KHM023 | កែប | ១ | នាក់ | ២៣ |
| ២៤ | 004KHM024 | ប៉ៃលិន | ៥ | នាក់ | ១២៨ |
| ២៥ | 004KHM025 | ត្បូងឃ្មុំ | ០ | នាក់ | ០ |
| | **សរុប** | | **១៩៩** | **នាក់** | **៥ ៤៤០** |